| ៤ | អាករលើតម្លៃបន្ថែម (១០% នៃ ១+២+៣) | ០,០៥០៥ ដុល្លារ | ០,០[illegible]២០ ដុល្លារ |
| ៥ | ថ្លៃលក់រាយ/លីត្រ (គិតជាដុល្លារ) | ០,៥៥៥៣ ដុល្លារ | ០,[illegible]២៣ ដុល្លារ |
| ៦ | ថ្លៃលក់រាយ/លីត្រ (គិតជារៀល) | ២.២៥២ រៀល | [illegible]២១ រៀល |
| ៧ | តម្លៃដែលត្រូវដាក់លក់រាយ/លីត្រ (គិតជាដុល្លារ) | ០,៥៦ ដុល្លារ | ០,៥៧ ដុល្លារ |
| ៨ | តម្លៃដែលត្រូវដាក់លក់រាយ/លីត្រ (គិតជារៀល) | ២.២៥០ រៀល | ២.៣០០ រៀល |

សម្គាល់៖ អត្រាប្តូរប្រាក់ផ្លូវការ ថ្ងៃទី១៦ ខែមេសា ឆ្នាំ២០២០ ដែលស្មើនឹង ៤០៥៥រៀល/ដុល្លារអាមេរិក

ឡូត៍លេខ ១៩-៦១ មហាវិថីសហព័ន្ធរុស្ស៊ី ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ / ទូរសារ: (៨៥៥)-២៣ ៨៦៦ ៤៦៩
Lot 19-61, Russian Federation Blvd, Phum Teuk Thla, Sangkat Teuk Thla, Khan Sen Sok, Phnom Penh, Kingdom of CAMBODIA Phone/Facsimile: (855)-23 866 469

### តារាងថ្លៃលក់រាយប្រេងឥន្ធនៈនៅលើទីផ្សារអន្តរជាតិ

| ថ្ងៃខែឆ្នាំ | ប្រេងសាំងធម្មតា/ធុង<br>EA 92 (USD/Barrel) | ប្រេងម៉ាស៊ូត/ធុង<br>DO 0.05% (USD/Barrel) |
|---|---|---|
| ១ មេសា ២០២០ | ១៨,០១ | ៣៥,០៧ |
| ២ មេសា ២០២០ | ២០,៦៥ | ៣៤,៨២ |
| ៣ មេសា ២០២០ | ២១,៩៧ | ៣៥,៩៥ |
| ៦ មេសា ២០២០ | ២២,៥២ | ៣៧,៥២ |
| ៧ មេសា ២០២០ | ២២,៩៧ | ៣៧,១៣ |
| ៨ មេសា ២០២០ | ១៩,៣២ | ៣៦,២៣ |
| ៩ មេសា ២០២០ | ២០,២៩ | ៣៥,៧៩ |
| ១៣ មេសា ២០២០ | ១៦,៩៧ | ៣៣,៣២ |
| ១៤ មេសា ២០២០ | ១៨,២៤ | ៣៣,៦០ |
| ១៥ មេសា ២០២០ | ១៨,៩៤ | ៣១,៤៧ |
| **មធ្យមភាគ ១០ថ្ងៃ** | **១៩,៩៨៨០** | **៣៥,០៩០០** |
| **មធ្យមភាគ (ដុល្លារ/លីត្រ)** | **០,១២៥៧** | **០,២២០៧** |

### ក្រាហ្វិកបម្រែបម្រួលថ្លៃលក់រាយប្រេងឥន្ធនៈពីថ្ងៃទី០១ ខែកុម្ភៈ ដល់ ១៦ ខែមេសា ឆ្នាំ២០២០




សូមបញ្ជាក់ថា ក្រសួងពាណិជ្ជកម្មមិនមែនជាអ្នកកំណត់ថ្លៃលក់រាយប្រេងឥន្ធនៈនៅកម្ពុជាទេ គឺក្រសួងគ្រាន់តែស្រង់តម្លៃឡើង-ចុះ នៃប្រេងតាមទីផ្សារអន្តរជាតិ មកគណនាតាមប្រកាសដូចមានក្នុងឯកសារយោងខាងលើតែប៉ុណ្ណោះ ។

អាស្រ័យហេតុនេះ សូមសាធារណៈជនមេត្តាជ្រាបជាព័ត៌មាន និងសូមគ្រប់ស្ថានីយលក់រាយប្រេងឥន្ធនៈទាំងអស់ ប្រតិបត្តិតាមការចាំបាច់។

## សន្ទស្សន៍ថ្លៃប្រេងឥន្ធនៈ នៅរាជធានីភ្នំពេញ ប្រចាំសប្តាហ៍ទី០៣ ខែមេសា ឆ្នាំ២០២០

| ល.រ | រាយមុខទំនិញ | Items | ឯកតា | ថ្លៃគ្រាគោល | ថ្លៃ | | | | | មធ្យម | ភាគរយ |
|---|---|---|---|---|---|---|---|---|---|---|---|
| No. | | | Unit | 02.01.2020 | ច័ន្ទ | អង្គារ | ពុធ | ព្រហស្បត្តិ៍ | សុក្រ | Average | (%) |
| 1 | 2 | | 3 | 4 | 5 | 6 | 7 | 8 | 9 | 10 | 10/4 |
| I | ក្រុមហ៊ុន សូគីម៉ិច | Sokimex | R/L | | | | | | | | |
| | សាំងស៊ុបពែរ | EA 95 (Super) | - | 4,150 | 2,750 | 2,750 | 2,750 | 2,750 | 2,750 | 2,750 | ▼ -33.73 % |
| | សាំងធម្មតា | EA 92 (Regular) | - | 3,750 | 2,250 | 2,250 | 2,250 | 2,250 | 2,250 | 2,250 | ▼ -40.00 % |
| | ប្រេងម៉ាស៊ូត | DO 0.05% | - | 3,650 | 2,300 | 2,300 | 2,300 | 2,300 | 2,300 | 2,300 | ▼ -36.99 % |
| II | ក្រុមហ៊ុន តេលា | Tela | | | | | | | | | |
| | សាំងស៊ុបពែរ | EA 95 (Super) | - | 4,150 | 2,700 | 2,700 | 2,700 | 2,700 | 2,700 | 2,700 | ▼ -34.94 % |
| | សាំងធម្មតា | EA 92 (Regular) | - | 3,750 | 2,250 | 2,250 | 2,250 | 2,250 | 2,250 | 2,250 | ▼ -40.00 % |
| | ប្រេងម៉ាស៊ូត | DO 0.05% | - | 3,650 | 2,300 | 2,300 | 2,300 | 2,300 | 2,300 | 2,300 | ▼ -36.99 % |
| III | ក្រុមហ៊ុន ឈេវរ៉ុន | Caltex (Chevron) | - | | | | | | | | |
| | សាំងស៊ុបពែរ | EA 95 (Super) | - | 4,150 | 2,750 | 2,750 | 2,750 | 2,750 | 2,750 | 2,750 | ▼ -33.73 % |
| | សាំងធម្មតា | EA 92 (Regular) | - | 3,750 | 2,250 | 2,250 | 2,250 | 2,250 | 2,250 | 2,250 | ▼ -40.00 % |
| | ប្រេងម៉ាស៊ូត | DO 0.05% | - | 3,650 | 2,300 | 2,300 | 2,300 | 2,300 | 2,300 | 2,300 | ▼ -36.99 % |
| VI | ក្រុមហ៊ុន តូតាល់ | Total | - | | | | | | | | |
| | សាំងស៊ុបពែរ | EA 95 (Super) | - | 4,150 | 2,650 | 2,650 | 2,650 | 2,650 | 2,650 | 2,650 | ▼ -36.14 % |
| | សាំងធម្មតា | EA 92 (Regular) | - | 3,750 | 2,250 | 2,250 | 2,250 | 2,250 | 2,250 | 2,250 | ▼ -40.00 % |
| | ប្រេងម៉ាស៊ូត | DO 0.05% | - | 3,650 | 2,300 | 2,300 | 2,300 | 2,300 | 2,300 | 2,300 | ▼ -36.99 % |
| V | ក្រុមហ៊ុន ភីធីធី | PTT | - | | | | | | | | |
| | សាំងស៊ុបពែរ | EA 95 (Super) | - | 4,100 | 2,650 | 2,650 | 2,650 | 2,650 | 2,650 | 2,650 | ▼ -35.37 % |
| | សាំងធម្មតា | EA 92 (Regular) | - | 3,750 | 2,250 | 2,250 | 2,250 | 2,250 | 2,250 | 2,250 | ▼ -40.00 % |
| | ប្រេងម៉ាស៊ូត | DO 0.05% | - | 3,650 | 2,300 | 2,300 | 2,300 | 2,300 | 2,300 | 2,300 | ▼ -36.99 % |

| ល.រ No. | រាយមុខទំនិញ | Items | ឯកតា Unit | ថ្លៃគ្រាគោល 02.01.2020 | ថ្លៃ ច័ន្ទ | អង្គារ | ពុធ | ព្រហស្បត្តិ៍ | សុក្រ | មធ្យម Average | ភាគរយ (%) |
|---|---|---|---|---|---|---|---|---|---|---|---|
| VI | ក្រុមហ៊ុន សាវីមិច | Savimex | - | | | | | | | | |
| | សាំងស៊ុបពែរ | EA 95 (Super) | - | 3,700 | 2,500 | 2,500 | 2,500 | 2,500 | 2,500 | 2,500 | -32.43 % |
| | សាំងធម្មតា | EA 92 (Regular) | - | 3,600 | 2,200 | 2,200 | 2,200 | 2,200 | 2,200 | 2,200 | -38.89 % |
| | ប្រេងម៉ាស៊ូត | DO 0.05% | - | 3,400 | 2,200 | 2,200 | 2,200 | 2,200 | 2,200 | 2,200 | -35.29 % |
| VII | ក្រុមហ៊ុន អិល អេច អរ | LHR | - | | | | | | | | |
| | សាំងស៊ុបពែរ | EA 95 (Super) | - | 3,600 | 2,500 | 2,500 | 2,500 | 2,500 | 2,500 | 2,500 | -30.56 % |
| | សាំងធម្មតា | EA 92 (Regular) | - | 3,400 | 2,150 | 2,150 | 2,150 | 2,150 | 2,150 | 2,150 | -36.76 % |
| | ប្រេងម៉ាស៊ូត | DO 0.05% | - | 3,300 | 2,200 | 2,200 | 2,200 | 2,200 | 2,200 | 2,200 | -33.33 % |
| VIII | ក្រុមហ៊ុន ប៊ីវីអឹម | BVM | - | | | | | | | | |
| | សាំងស៊ុបពែរ | EA 95 (Super) | - | 3,500 | 2,500 | 2,500 | 2,500 | 2,500 | 2,500 | 2,500 | -28.57 % |
| | សាំងធម្មតា | EA 92 (Regular) | - | 3,300 | 2,200 | 2,200 | 2,200 | 2,200 | 2,200 | 2,200 | -33.33 % |
| | ប្រេងម៉ាស៊ូត | DO 0.05% | - | 3,000 | 2,200 | 2,200 | 2,200 | 2,200 | 2,200 | 2,200 | -26.67 % |
| IX | ក្រុមហ៊ុន លឹមឡុង | LIM LONG | - | | | | | | | | |
| | សាំងស៊ុបពែរ | EA 95 (Super) | - | 3,700 | 2,550 | 2,550 | 2,550 | 2,550 | 2,550 | 2,550 | -31.08 % |
| | សាំងធម្មតា | EA 92 (Regular) | - | 3,500 | 2,150 | 2,150 | 2,150 | 2,150 | 2,150 | 2,150 | -38.57 % |
| | ប្រេងម៉ាស៊ូត | DO 0.05% | - | 3,300 | 2,200 | 2,200 | 2,200 | 2,200 | 2,200 | 2,200 | -33.33 % |
| X | ក្រុមហ៊ុន ប៉ាប៉ា | LIM LONG | - | | | | | | | | |
| | សាំងស៊ុបពែរ | EA 95 (Super) | - | 4,150 | 2,700 | 2,700 | 2,700 | 2,700 | 2,700 | 2,700 | -34.94 % |
| | សាំងធម្មតា | EA 92 (Regular) | - | 3,650 | 2,150 | 2,150 | 2,150 | 2,150 | 2,150 | 2,150 | -41.10 % |
| | ប្រេងម៉ាស៊ូត | DO 0.05% | - | 3,550 | 2,200 | 2,200 | 2,200 | 2,200 | 2,200 | 2,200 | -38.03 % |

Table title: **សន្ទស្សន៍ថ្លៃប្រេងឥន្ធនៈ នៅរាជធានីភ្នំពេញ ប្រចាំសប្តាហ៍ទី០៣ ខែមេសា ឆ្នាំ២០២០**

*__ប្រភព៖__ ចុះពិនិត្យតាមស្ថានីយ៍ប្រេង (Sokimex, Caltex, Total, Tela, PTT, Savimex, LHR, BVM, LIM LONG)*

# សន្ទស្សន៍ថ្លៃប្រេងឥន្ធនៈ នៅរាជធានីភ្នំពេញ ប្រចាំសប្តាហ៍ទី០៤ ខែមេសា ឆ្នាំ២០២០

| ល.រ | រាយមុខទំនិញ | Items | ឯកតា | ថ្លៃគ្រាគោល | ថ្លៃ | | | | | មធ្យម | ភាគរយ |
|---|---|---|---|---|---|---|---|---|---|---|---|
| No. | | | Unit | 02.01.2020 | ច័ន្ទ | អង្គារ៍ | ពុធ | ព្រហស្បត្តិ៍ | សុក្រ | Average | (%) |
| 1 | 2 | | 3 | 4 | 5 | 6 | 7 | 8 | 9 | 10 | 10/4 |
| I | ក្រុមហ៊ុន សូគីមិច | Sokimex | R/L | | | | | | | | |
| | សាំងស៊ុបពែរ | EA 95 (Super) | - | 4,150 | 2,750 | 2,750 | 2,750 | 2,750 | 2,750 | 2,750 | -33.73 % |
| | សាំងធម្មតា | EA 92 (Regular) | - | 3,750 | 2,250 | 2,250 | 2,250 | 2,250 | 2,250 | 2,250 | -40.00 % |
| | ប្រេងម៉ាស៊ូត | DO 0.05% | - | 3,650 | 2,300 | 2,300 | 2,300 | 2,300 | 2,300 | 2,300 | -36.99 % |
| II | ក្រុមហ៊ុន តេលា | Tela | | | | | | | | | |
| | សាំងស៊ុបពែរ | EA 95 (Super) | - | 4,150 | 2,700 | 2,700 | 2,700 | 2,700 | 2,700 | 2,700 | -34.94 % |
| | សាំងធម្មតា | EA 92 (Regular) | - | 3,750 | 2,250 | 2,250 | 2,250 | 2,250 | 2,250 | 2,250 | -40.00 % |
| | ប្រេងម៉ាស៊ូត | DO 0.05% | - | 3,650 | 2,300 | 2,300 | 2,300 | 2,300 | 2,300 | 2,300 | -36.99 % |
| III | ក្រុមហ៊ុន កាលតិច | Caltex (Chevron) | - | | | | | | | | |
| | សាំងស៊ុបពែរ | EA 95 (Super) | - | 4,150 | 2,750 | 2,750 | 2,750 | 2,750 | 2,750 | 2,750 | -33.73 % |
| | សាំងធម្មតា | EA 92 (Regular) | - | 3,750 | 2,250 | 2,250 | 2,250 | 2,250 | 2,250 | 2,250 | -40.00 % |
| | ប្រេងម៉ាស៊ូត | DO 0.05% | - | 3,650 | 2,300 | 2,300 | 2,300 | 2,300 | 2,300 | 2,300 | -36.99 % |
| VI | ក្រុមហ៊ុន តូតាល់ | Total | - | | | | | | | | |
| | សាំងស៊ុបពែរ | EA 95 (Super) | - | 4,150 | 2,650 | 2,650 | 2,650 | 2,650 | 2,650 | 2,650 | -36.14 % |
| | សាំងធម្មតា | EA 92 (Regular) | - | 3,750 | 2,250 | 2,250 | 2,250 | 2,250 | 2,250 | 2,250 | -40.00 % |
| | ប្រេងម៉ាស៊ូត | DO 0.05% | - | 3,650 | 2,300 | 2,300 | 2,300 | 2,300 | 2,300 | 2,300 | -36.99 % |
| V | ក្រុមហ៊ុន ភីធីធី | PTT | - | | | | | | | | |
| | សាំងស៊ុបពែរ | EA 95 (Super) | - | 4,100 | 2,650 | 2,650 | 2,650 | 2,650 | 2,650 | 2,650 | -35.37 % |
| | សាំងធម្មតា | EA 92 (Regular) | - | 3,750 | 2,250 | 2,250 | 2,250 | 2,250 | 2,250 | 2,250 | -40.00 % |
| | ប្រេងម៉ាស៊ូត | DO 0.05% | - | 3,650 | 2,300 | 2,300 | 2,300 | 2,300 | 2,300 | 2,300 | -36.99 % |

| សន្ទស្សន៍ថ្លៃប្រេងឥន្ធនៈ នៅរាជធានីភ្នំពេញ ប្រចាំសប្តាហ៍ទី០៤ ខែមេសា ឆ្នាំ២០២០ | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|
| ល.រ | រាយមុខទំនិញ | Items | ឯកតា | ថ្លៃគ្រាគោល | ថ្លៃ | | | | | មធ្យម | ភាគរយ |
| No. | | | Unit | 02.01.2020 | ច័ន្ទ | អង្គារ៍ | ពុធ | ព្រហស្បត្តិ៍ | សុក្រ | Average | (%) |
| VI | ក្រុមហ៊ុន សាវីមិច | Savimex | - | | | | | | | | |
| | សាំងស៊ុបពែរ | EA 95 (Super) | - | 3,700 | 2,500 | 2,500 | 2,500 | 2,500 | 2,500 | 2,500 | -32.43 % |
| | សាំងធម្មតា | EA 92 (Regular) | - | 3,600 | 2,200 | 2,200 | 2,200 | 2,200 | 2,200 | 2,200 | -38.89 % |
| | ប្រេងម៉ាស៊ូត | DO 0.05% | - | 3,400 | 2,200 | 2,200 | 2,200 | 2,200 | 2,200 | 2,200 | -35.29 % |
| VII | ក្រុមហ៊ុន អិល អេច អរ | LHR | - | | | | | | | | |
| | សាំងស៊ុបពែរ | EA 95 (Super) | - | 3,600 | 2,500 | 2,500 | 2,500 | 2,500 | 2,500 | 2,500 | -30.56 % |
| | សាំងធម្មតា | EA 92 (Regular) | - | 3,400 | 2,150 | 2,150 | 2,150 | 2,150 | 2,150 | 2,150 | -36.76 % |
| | ប្រេងម៉ាស៊ូត | DO 0.05% | - | 3,300 | 2,200 | 2,200 | 2,200 | 2,200 | 2,200 | 2,200 | -33.33 % |
| VIII | ក្រុមហ៊ុន ប៊ីវីអឹម | BVM | - | | | | | | | | |
| | សាំងស៊ុបពែរ | EA 95 (Super) | - | 3,500 | 2,500 | 2,500 | 2,500 | 2,500 | 2,500 | 2,500 | -28.57 % |
| | សាំងធម្មតា | EA 92 (Regular) | - | 3,300 | 2,200 | 2,200 | 2,200 | 2,200 | 2,200 | 2,200 | -33.33 % |
| | ប្រេងម៉ាស៊ូត | DO 0.05% | - | 3,000 | 2,200 | 2,200 | 2,200 | 2,200 | 2,200 | 2,200 | -26.67 % |
| IX | ក្រុមហ៊ុន លឹមឡុង | LIM LONG | - | | | | | | | | |
| | សាំងស៊ុបពែរ | EA 95 (Super) | - | 3,700 | 2,550 | 2,550 | 2,550 | 2,550 | 2,550 | 2,550 | -31.08 % |
| | សាំងធម្មតា | EA 92 (Regular) | - | 3,500 | 2,150 | 2,150 | 2,150 | 2,150 | 2,150 | 2,150 | -38.57 % |
| | ប្រេងម៉ាស៊ូត | DO 0.05% | - | 3,300 | 2,200 | 2,200 | 2,200 | 2,200 | 2,200 | 2,200 | -33.33 % |
| X | ក្រុមហ៊ុន ប៉ាប៉ា | LIM LONG | - | | | | | | | | |
| | សាំងស៊ុបពែរ | EA 95 (Super) | - | 4,150 | 2,700 | 2,700 | 2,700 | 2,700 | 2,700 | 2,700 | -34.94 % |
| | សាំងធម្មតា | EA 92 (Regular) | - | 3,650 | 2,150 | 2,150 | 2,150 | 2,150 | 2,150 | 3300 | 3300 |
| | ប្រេងម៉ាស៊ូត | DO 0.05% | - | 3,550 | 2,200 | 2,200 | 2,200 | 2,200 | 2,200 | 2,200 | -38.03 % |

***ប្រភព៖*** *ចុះពិនិត្យតាមស្ថានីយ៍ប្រេង (Sokimex, Caltex, Total, Tela, PTT, Savimex, LHR, BVM, LIM LONG)*

-អត្រាប្តូរប្រាក់របស់ធនាគារជាតិ នៃកម្ពុជា ថ្ងៃទី២៣ ខែមេសា ឆ្នាំ២០២០

| រូបិយណប័ណ្ណ | និមិត្តសញ្ញា | ឯកតា | ទិញ | លក់ | មធ្យម |
|---|---|---|---|---|---|
| ដុល្លារអូស្ត្រាលី | AUD/KHR | ១ | ២៥៩៨ | ២៦២៤ | ២៦១១.00 |
| ដុល្លារកាណាដា | CAD/KHR | ១ | ២៩០០ | ២៩២៩ | ២៩១៤.៥0 |
| ហ្វ្រង់ស្វីស | CHF/KHR | ១ | ៤១៧៨ | ៤២២០ | ៤១៩៩.00 |
| យ័ន់ចិននៅហុងកុង | CNH/KHR | ១ | ៥៧៥ | ៥៨១ | ៥៧៨.00 |
| យ័ន់ចិន | CNY/KHR | ១ | ៥៧៧ | ៥៨៣ | ៥៨០.00 |
| អឺរ៉ូ | EUR/KHR | ១ | ៤៣៩៥ | ៤៤៣៩ | ៤៤១៧.00 |
| ផោនអង់គ្លេស | GBP/KHR | ១ | ៥០៤០ | ៥០៩០ | ៥០៦៥.00 |
| ដុល្លារហុងកុង | HKD/KHR | ១ | ៥២៦ | ៥៣២ | ៥២៩.00 |
| រ៉ូពីឥណ្ឌូនេស៊ី | IDR/KHR | ១000 | ២៦៥ | ២៦៨ | ២៦៦.៥0 |
| រ៉ូពីឥណ្ឌា | INR/KHR | ១00 | ៥៣៦៤ | ៥៤១៧ | ៥៣៩០.៥0 |
| យេនជប៉ុន | JPY/KHR | ១00 | ៣៧៩០ | ៣៨២៨ | ៣៨០៩.00 |
| វុនកូរ៉េ | KRW/KHR | ១00 | ៣៣០ | ៣៣៤ | ៣៣២.00 |
| គីបឡាវ | LAK/KHR | ១000 | ៤៥៩ | ៤៦៤ | ៤៦១.៥0 |
| មីយ៉ាន់ម៉ាក្យាត | MMK/KHR | ១00 | ២៨៥ | ២៨៩ | ២៨៧.៥0 |
| រីងហ្គីតម៉ាឡេស៊ី | MYR/KHR | ១ | ៩៣៧ | ៩៤៦ | ៩៤១.៥0 |
| ដុល្លារញូស៊ីឡែន | NZD/KHR | ១ | ២៤៤៦ | ២៤៧១ | ២៤៥៨.៥0 |
| ប៉េសូហ្វីលីពីន | PHP/KHR | ១00 | ៨០៥២ | ៨១៣៣ | ៨០៩២.៥0 |
| អេស ដេ អា | SDR/KHR | ១ | ៥៥៤៧ | ៥៦០២ | ៥៥៧៤.៥0 |
| ក្រូណាស៊ុយអែត | SEK/KHR | ១ | ៤០៥ | ៤០៩ | ៤០៧.00 |
| ដុល្លារសិង្ហបុរី | SGD/KHR | ១ | ២៨៦២ | ២៨៩១ | ២៨៧៦.៥0 |
| បាតថៃ | THB/KHR | | ១២៦ | ១២៨ | ១២៧.00 |
| ដុល្លារតៃវ៉ាន់ | TWD/KHR | | ១៣៦ | ១៣៧ | ១៣៦.៥0 |
| ដុងវៀតណាម | VND/KHR | ១000 | ១៧៤ | ១៧៥ | ១៧៤.៥0 |

ប្រភព៖ ធនាគាជាតិ នៃកម្ពុជា

-តម្លៃមាសក្នុងស្រុក៖

**II -Local Gold**

| GOLD UNIT | Gold Rate | | | | | |
|---|---|---|---|---|---|---|
| | 16 Apr,2020 07:00:00 | 18 Apr,2020 07:00:00 | 20 Apr ,2020 07:00:00 | 21 Apr,2020 07:00:00 | 22 Apr ,2020 07:00:00 | 24 Apr ,2020 07:00:00 |
| Ounce | $1,701.10 | $1,702.75 | $1,716.35 | $1,710.00 | $1,726.35 | $1,735.00 |
| Kilogram | $54,691.63 | $54,701.50 | $54,803.44 | $55,790.50 | $55,503.44 | $55,781.55 |
| Gram 24K | $54.69 | $54.80 | $54.9 | $54.62 | $55.50 | $55.78 |
| Gram 22K | $52.20 | $52.50 | $52.90 | $52.50 | $53.90 | $54.00 |
| Gram 21K | $50.90 | $51.00 | $50.95 | $50.00 | $51.95 | $52.30 |
| Gram 18K | $45.95 | $46.00 | $46.75 | $45.90 | $47.05 | $48.10 |

Price Courtesy of LY HOUR Exchange 26.67 Damlungs are equal to 1 Kg

-អត្រាប្តូរប្រាក់ក្នុងស្រុក៖

| Currency | Unit | Apr .16 , 2020 (8:00:00) | | Apr .24 , 2020 (8:00:00) | |
|---|---|---|---|---|---|
| | | Bid | Bid | Bid | Bid |
| Riel. Cambodia | 1 USD | 4.075 | 4,098 | 4.095 | 4,120 |
| B. Thailand | 1 USD | 0.5969 | 0.6131 | 0.5981 | 0.6745 |
| D.Veitnam | 1USD | 1.0431 | 1.1300 | 1.0338 | 1.1199 |
| Y. Japan | 10,000JPY | 1.1865 | 1.3114 | 1.1737 | 1.2973 |
| $.Singapore | 100SGD | 1.3190 | 1.4904 | 1.3222 | 1.4940 |
| $.Hong Kong | 100HKD | 0.9390 | 0.9971 | 0.9476 | 1.0062 |
| Ringuit. Malaysia | 100 MYR | 6.8969 | 7.2505 | 6.8901 | 7.2435 |
| Euro | 100EUR | 7.5185 | 7.9835 | 7.5185 | 7.9835 |
| £.English | 100 JBP | 101.86 | 113.72 | 101.80 | 113.64 |
| $.Canada | 100 CAD | 4.2282 | 4.5168 | 4.2232 | 4.5114 |
| $.Australia | 100 AUD | 1.3661 | 1.4799 | 1.3692 | 1.4832 |
| F. Swiss | 100 GHF | 31.89 | 33.05 | 31.79 | 32.95 |

ប្រភព៖ លីហួរ អត្រាប្តូរប្រាក់








# សន្ទស្សន៍ថ្លៃ ស្រូវ អង្ករ និង ហ្កាស នៅតាមបណ្តារាជធានី-ខេត្ត ប្រចាំសប្តាហ៍ទី០៣ ខែមេសា ឆ្នាំ២០២០

| 3 | រាជធានី-ខេត្ត | សប្តាហ៍ទី១ ខែមករា ឆ្នាំ២០២០ (រៀល/គក្រ) | | | | | សប្តាហ៍ទី០៣ ខែមេសា ឆ្នាំ២០២០ (រៀល/គក្រ) | | | | | | | | | | ស្តុកស្រូវ /តោន | ស្តុកអង្ករ /តោន |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | អង្ករលេខ១ ឬអង្ករផ្កាខ្ញី | អង្ករលេខ២ ឬអង្ករនាងមិញ | អង្ករ IR ឬអង្ករចំរុះ | ស្រូវចំរុះ | ហ្កាស ១៥ គីឡូក្រាម | អង្ករលេខ១ ឬអង្ករផ្កាខ្ញី | % | អង្ករលេខ២ ឬអង្ករនាងមិញ | % | អង្ករ IR ឬអង្ករចំរុះ | % | ស្រូវចំរុះ | % | ហ្កាស ១៥ គីឡូក្រាម | % | | |
| 1 | ភ្នំពេញ | 2,600 | 2,500 | 1,800 | 2,000 | 65,000 | 2,600 | 0.00 | 2,500 | 0.00 | - | - | 2,500 | 25.00 | 65,000 | 0.00 | | 680 |
| 2 | កណ្តាល | 2,300 | 2,000 | 1,900 | 1,300 | 50,000 | 1,900 | -17.39 | 2,000 | 0.00 | 1,800 | -5.26 | 1,000 | -23.08 | 60,000 | 20.00 | 2,810 | 280 |
| 3 | កំពង់ស្ពឺ | 2,300 | 2,000 | 1,900 | 1,200 | 65,280 | 2,300 | 0.00 | 2,000 | 0.00 | 1,700 | -10.53 | 950 | -20.83 | 65,600 | 0.49 | 1,862 | 37,186 |
| 4 | តាកែវ | 2,800 | 2,400 | 1,140 | 1,100 | 53,000 | 2,400 | -14.29 | 2,100 | -12.50 | 1,600 | 40.35 | 950 | -13.64 | 63,000 | 18.87 | 78,653 | 49,761 |
| 5 | កំពត | 2,400 | 1,700 | 1,700 | 950 | 58,000 | 2,700 | 12.50 | 1,700 | 0.00 | 1,700 | 0.00 | 950 | 0.00 | 58,000 | 0.00 | 62,342 | 63,104 |
| 6 | ព្រៃវែង | 3,000 | - | 1,800 | 1,000 | 55,000 | 3,000 | 0.00 | - | - | 2,000 | 11.11 | 950 | -5.00 | 53,000 | -3.64 | 227,067 | 9,000 |
| 7 | ស្វាយរៀង | 3,000 | 2,200 | 2,000 | 900 | 39,000 | 3,000 | 0.00 | 2,200 | 0.00 | 2,000 | 0.00 | 850 | -5.56 | 48,000 | 23.08 | 115,430 | 98 |
| 8 | កំពង់ចាម | 3,400 | 2,200 | 2,200 | 1,000 | 61,000 | 3,500 | 2.94 | 2,500 | 13.64 | 2,200 | 0.00 | 1,000 | 0.00 | 62,000 | 1.64 | 15,730 | 150 |
| 9 | កំពង់ធំ | 3,000 | 2,000 | 2,000 | 870 | 51,510 | 2,800 | -6.67 | 2,100 | 5.00 | 1,800 | -10.00 | 850 | -2.30 | 51,510 | 0.00 | 58,262 | 37,288 |
| 10 | ព្រះវិហារ | 3,000 | 2,100 | 2,200 | 850 | 60,000 | 3,000 | 0.00 | 2,200 | 4.76 | 2,200 | 0.00 | 850 | 0.00 | 60,000 | 0.00 | 47,260 | 500 |
| 11 | ក្រចេះ | 2,000 | 2,000 | 1,700 | 1,000 | 76,176 | 2,000 | 0.00 | 2,000 | 0.00 | 1,700 | 0.00 | 1,000 | 0.00 | - | - | 39,443 | 55 |
| 12 | ស្ទឹងត្រែង | 2,600 | 2,000 | 1,700 | 900 | 65,000 | 2,600 | 0.00 | 2,000 | 0.00 | 1,700 | 0.00 | 700 | -22.22 | 65,000 | 0.00 | 14,341 | 3,000 |
| 13 | រតនះគិរី | 3,000 | 1,700 | 1,510 | 1,700 | 65,000 | 2,550 | -15.00 | 1,560 | -8.24 | 1,560 | 3.31 | 950 | -44.12 | 65,000 | 0.00 | 1,230 | 210 |
| 14 | មណ្ឌលគីរី | 3,800 | 2,200 | 2,200 | 1,000 | 60,000 | 2,800 | -26.32 | 2,000 | -9.09 | 2,000 | -9.09 | 700 | -30.00 | 60,000 | 0.00 | 800 | 35 |
| 15 | កំពង់ឆ្នាំង | 3,100 | 2,200 | 1,900 | 1,150 | 50,000 | 3,000 | -3.23 | 2,100 | -4.55 | 1,800 | -5.26 | 900 | -21.74 | 54,000 | 8.00 | 54,045 | 110,000 |
| 16 | ពោធិសាត់ | 2,600 | 2,580 | 1,750 | 800 | 56,000 | 2,600 | 0.00 | 2,500 | -3.10 | 1,700 | -2.86 | 900 | 12.50 | 51,100 | -8.75 | 13,500 | 60 |
| 17 | បាត់ដំបង | 2,500 | 2,000 | 1,700 | 967 | 60,000 | 2,500 | 0.00 | 2,000 | 0.00 | 1,800 | 5.88 | - | - | 60,000 | 0.00 | 100,000 | 46,832 |
| 18 | បន្ទាយមានជ័យ | 2,600 | 2,000 | 2,000 | 711 | - | 2,600 | 0.00 | 2,000 | 0.00 | 2,000 | 0.00 | 630 | -11.39 | - | - | 68,600 | 12,100 |
| 19 | សៀមរាប | 2,500 | 2,000 | 1,650 | 900 | 56,000 | 2,500 | 0.00 | 2,400 | 20.00 | 1,100 | -33.33 | 900 | 0.00 | 54,000 | -3.57 | 4,800 | 2,880 |
| 20 | កោះកុង | 3,100 | 2,100 | 2,000 | 1,600 | 64,000 | 3,000 | -3.23 | 2,000 | -4.76 | 2,000 | 0.00 | 1,600 | 0.00 | 63,000 | -1.56 | 15,498 | 165 |
| 21 | ព្រះសីហនុ | 2,900 | 2,300 | 1,800 | 1,200 | 72,000 | 3,000 | 3.45 | 2,300 | 0.00 | 1,700 | -5.56 | 1,200 | 0.00 | 70,000 | -2.78 | 1,000 | 328,000 |
| 22 | កែប | 2,400 | 2,300 | 1,700 | 1,050 | 54,000 | 2,400 | 0.00 | 2,000 | -13.04 | 1,700 | 0.00 | 1,150 | 9.52 | 63,000 | 16.67 | 5,423 | 55 |
| 23 | ប៉ៃលិន | 2,800 | 2,000 | 1,800 | 800 | 55,000 | 3,000 | 7.14 | 2,300 | 15.00 | 2,000 | 11.11 | 750 | -6.25 | 60,000 | 9.09 | 30 | 90 |
| 24 | ឧត្តរមានជ័យ | 1,600 | 1,800 | 1,600 | 700 | 75,000 | 1,600 | 0.00 | 1,500 | -16.67 | 1,600 | 0.00 | 700 | 0.00 | 76,000 | 1.33 | 10,000 | 240 |
| 25 | ត្បូងឃ្មុំ | 2,800 | 2,800 | 1,900 | 930 | 61,000 | 2,800 | 0.00 | 1,900 | -32.14 | 1,900 | 0.00 | 950 | 2.15 | 57,000 | -6.56 | 142,420 | 2,165 |
| | | | | | | | | | | | | | | | | | **1,080,546** | **703,934** |

*ប្រភព : មន្ទីរពាណិជ្ជកម្មរាជធានី - ខេត្ត*

# សន្ទស្សន៍ថ្លៃ ស្រូវ អង្ករ និង ហ្គាស នៅតាមបណ្ដារាជធានី-ខេត្ត ប្រចាំសប្ដាហ៍ទី០៤ ខែមេសា ឆ្នាំ២០២០

| 3 | រាជធានី-ខេត្ត | សប្ដាហ៍ទី១ ខែមករា ឆ្នាំ២០២០ (រៀល/គក្រ) | | | | | សប្ដាហ៍ទី០៤ ខែមេសា ឆ្នាំ២០២០ (រៀល/គក្រ) | | | | | | | | | | ស្តុកស្រូវ /តោន | ស្តុកអង្ករ /តោន |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | អង្ករលេខ១ ឬអង្ករផ្កាខ្ញី | អង្ករលេខ២ ឬអង្ករនាងមិញ | អង្ករ IR ឬអង្ករចំរុះ | ស្រូវចំរុះ | ហ្គាស ១៥ គីឡូក្រាម | អង្ករលេខ១ ឬអង្ករផ្កាខ្ញី | % | អង្ករលេខ២ ឬអង្ករនាងមិញ | % | អង្ករ IR ឬអង្ករចំរុះ | % | ស្រូវចំរុះ | % | ហ្គាស ១៥ គីឡូក្រាម | % | | |
| 1 | ភ្នំពេញ | 2,600 | 2,500 | 1,800 | 2,000 | 65,000 | 2,600 | 0.00 | 2,500 | 0.00 | - | - | 2,500 | 25.00 | 65,000 | 0.00 | | 680 |
| 2 | កណ្ដាល | 2,300 | 2,000 | 1,900 | 1,300 | 50,000 | 1,900 | -17.39 | 2,000 | 0.00 | 1,800 | -5.26 | 1,000 | -23.08 | 60,000 | 20.00 | 2,810 | 280 |
| 3 | កំពង់ស្ពឺ | 2,300 | 2,000 | 1,900 | 1,200 | 65,280 | 2,300 | 0.00 | 2,000 | 0.00 | 1,700 | -10.53 | 950 | -20.83 | 65,600 | 0.49 | 1,862 | 37,186 |
| 4 | តាកែវ | 2,800 | 2,400 | 1,140 | 1,100 | 53,000 | 2,400 | -14.29 | 2,100 | -12.50 | 1,600 | 40.35 | 950 | -13.64 | 63,000 | 18.87 | 78,653 | 49,761 |
| 5 | កំពត | 2,400 | 1,700 | 1,700 | 950 | 58,000 | 2,700 | 12.50 | 1,700 | 0.00 | 1,700 | 0.00 | 950 | 0.00 | 58,000 | 0.00 | 62,342 | 63,104 |
| 6 | ព្រៃវែង | 3,000 | - | 1,800 | 1,000 | 55,000 | 3,000 | 0.00 | - | - | 2,000 | 11.11 | 950 | -5.00 | 53,000 | -3.64 | 227,067 | 9,000 |
| 7 | ស្វាយរៀង | 3,000 | 2,200 | 2,000 | 900 | 39,000 | 3,000 | 0.00 | 2,200 | 0.00 | 2,000 | 0.00 | 850 | -5.56 | 48,000 | 23.08 | 115,430 | 98 |
| 8 | កំពង់ចាម | 3,400 | 2,200 | 2,200 | 1,000 | 61,000 | 3,500 | 2.94 | 2,500 | 13.64 | 2,200 | 0.00 | 1,000 | 0.00 | 62,000 | 1.64 | 15,730 | 150 |
| 9 | កំពង់ធំ | 3,000 | 2,000 | 2,000 | 870 | 51,510 | 2,800 | -6.67 | 2,100 | 5.00 | 1,800 | -10.00 | 850 | -2.30 | 51,510 | 0.00 | 58,262 | 37,288 |
| 10 | ព្រះវិហារ | 3,000 | 2,100 | 2,200 | 850 | 60,000 | 3,000 | 0.00 | 2,200 | 4.76 | 2,200 | 0.00 | 850 | 0.00 | 60,000 | 0.00 | 47,260 | 500 |
| 11 | ក្រចេះ | 2,000 | 2,000 | 1,700 | 1,000 | 76,176 | 2,000 | 0.00 | 2,000 | 0.00 | 1,700 | 0.00 | 1,000 | 0.00 | - | - | 39,443 | 55 |
| 12 | ស្ទឹងត្រែង | 2,600 | 2,000 | 1,700 | 900 | 65,000 | 2,600 | 0.00 | 2,000 | 0.00 | 1,700 | 0.00 | 700 | -22.22 | 65,000 | 0.00 | 14,341 | 3,000 |
| 13 | រតនះគីរី | 3,000 | 1,700 | 1,510 | 1,700 | 65,000 | 2,550 | -15.00 | 1,560 | -8.24 | 1,560 | 3.31 | 950 | -44.12 | 65,000 | 0.00 | 1,230 | 210 |
| 14 | មណ្ឌលគីរី | 3,800 | 2,200 | 2,200 | 1,000 | 60,000 | 2,800 | -26.32 | 2,000 | -9.09 | 2,000 | -9.09 | 700 | -30.00 | 60,000 | 0.00 | 800 | 35 |
| 15 | កំពង់ឆ្នាំង | 3,100 | 2,200 | 1,900 | 1,150 | 50,000 | 3,000 | -3.23 | 2,100 | -4.55 | 1,800 | -5.26 | 900 | -21.74 | 54,000 | 8.00 | 54,045 | 110,000 |
| 16 | ពោធិសាត់ | 2,600 | 2,580 | 1,750 | 800 | 56,000 | 2,600 | 0.00 | 2,500 | -3.10 | 1,700 | -2.86 | 900 | 12.50 | 51,100 | -8.75 | 13,500 | 60 |
| 17 | បាត់ដំបង | 2,500 | 2,000 | 1,700 | 967 | 60,000 | 2,500 | 0.00 | 2,000 | 0.00 | 1,800 | 5.88 | - | - | 60,000 | 0.00 | 100,000 | 46,832 |
| 18 | បន្ទាយមានជ័យ | 2,600 | 2,000 | 2,000 | 711 | - | 2,600 | 0.00 | 2,000 | 0.00 | 2,000 | 0.00 | 630 | -11.39 | - | - | 68,600 | 12,100 |
| 19 | សៀមរាប | 2,500 | 2,000 | 1,650 | 900 | 56,000 | 2,500 | 0.00 | 2,400 | 20.00 | 1,100 | -33.33 | 900 | 0.00 | 54,000 | -3.57 | 4,800 | 2,880 |
| 20 | កោះកុង | 3,100 | 2,100 | 2,000 | 1,600 | 64,000 | 3,000 | -3.23 | 2,000 | -4.76 | 2,000 | 0.00 | 1,600 | 0.00 | 63,000 | -1.56 | 15,498 | 165 |
| 21 | ព្រះសីហនុ | 2,900 | 2,300 | 1,800 | 1,200 | 72,000 | 3,000 | 3.45 | 2,300 | 0.00 | 1,700 | -5.56 | 1,200 | 0.00 | 70,000 | -2.78 | 1,000 | 328,000 |
| 22 | កែប | 2,400 | 2,300 | 1,700 | 1,050 | 54,000 | 2,400 | 0.00 | 2,000 | -13.04 | 1,700 | 0.00 | 1,150 | 9.52 | 63,000 | 16.67 | 5,423 | 55 |
| 23 | ប៉ៃលិន | 2,800 | 2,000 | 1,800 | 800 | 55,000 | 3,000 | 7.14 | 2,300 | 15.00 | 2,000 | 11.11 | 750 | -6.25 | 60,000 | 9.09 | 30 | 90 |
| 24 | ឧត្តរមានជ័យ | 1,600 | 1,800 | 1,600 | 700 | 75,000 | 1,600 | 0.00 | 1,500 | -16.67 | 1,600 | 0.00 | 700 | 0.00 | 76,000 | 1.33 | 10,000 | 240 |
| 25 | ត្បូងឃ្មុំ | 2,800 | 2,800 | 1,900 | 930 | 61,000 | 2,800 | 0.00 | 1,900 | -32.14 | 1,900 | 0.00 | 950 | 2.15 | 57,000 | -6.56 | 142,420 | 2,165 |
| | | | | | | | | | | | | | | | | | **1,080,546** | **703,934** |

*ប្រភព : មន្ទីរពាណិជ្ជកម្មរាជធានី - ខេត្ត*

## តម្លៃទំនិញប្រើប្រាស់ចាំបាច់សំខាន់ៗ លើទីផ្សារអន្តរជាតិ

**-ទីផ្សារអង្ករកម្ពុជាក្នុងរយៈពេល ២ខែដើមឆ្នាំ ២០២០៖**

ការនាំចេញអង្ករកម្ពុជា មានការកើនឡើងខ្ពស់ក្នុងរយៈពេល២ខែដើមឆ្នាំបានចំនួន ១៣៦,៤៩៩ តោន គឺកើន ២១,៣៤% ធៀបទៅនឹងរយៈពេលដូចគ្នានាឆ្នាំមុនៗ ក្នុងចំនួនខាងលើការនាំទៅប្រទេសចិន ដណ្តើមបានភាគរយខ្ពស់បំផុត ៣៧,៤៣%។ តាមសេចក្តីប្រកាសរបស់សារព័ត៌មាន Phnom Penh Post បានឲ្យដឹងថា យោងតាមតួរលេខថ្មីបំផុតរបស់ក្រសួងកសិកម្មកម្ពុជា ការនាំចេញអង្កររបស់ប្រទេសនេះ មានការកើនឡើងខ្ពស់បំផុតក្នុងរយៈពេល២ខែ ដើមឆ្នាំ ២០២០ គឺមានការកើនឡើង ២១,៣៤% ធៀបឆ្នាំទៅ។ ដែលក្នុងនោះ បរិមាណនាំចេញទៅកាន់ប្រទេសចិនកើនខ្ពស់បំផុត ៣៧,៤៣% ស្មើនឹង ៥១,០៩២តោន និងបន្ទាប់ជាទីផ្សារអឺរ៉ុប ៣០,៣១% ស្មើនឹង ៤១,៣៧៣តោន ។ សមាគមប្រជាជាតិអាស៊ីអគ្នេយ៍ហៅកាត់ថា ASEAN ១៨,៤៨% ស្មើនឹង ២៥,២៣១តោន និង ទីផ្សារផ្សេងទៀត ៣,៧៨%( ១៨,៨០៣តោន )។ បើតាមលោកប្រធានសមាគមនាំចេញអង្ករកម្ពុជា (CRF) បានឲ្យដឹងថា ការនាំចេញអង្កររបស់ប្រទេសនេះទៅកាន់ទីផ្សារគូរភាគីនានា គឺ មានការកើនឡើង។

នៅទីផ្សារអឺរ៉ុប ពន្ធនាំចូលអង្ករកម្ពុជា បានថយចុះពី ១៧៥ អឺរ៉ូ/តោន នៅឆ្នាំ ២០១៩ ចុះមកនៅត្រឹម ១៥០អឺរ៉ូ/តោន នៅឆ្នាំ ២០២០។ កត្តាខាងលើ បានជួយកម្ពុជា បានទូលាយទីផ្សារកាន់តែធំជាងនេះនៅអឺរ៉ុប និងទន្ទឹមនេះ លោកប្រធាន ក៏មានសង្ឃឹមថា អង្ករកម្ពុជានឹងទទួលបានអតិថិជនចិនកាន់តែថែមទៀត ដោយសារតែតម្រូវការមានការកើនឡើងពីសំនាក់ប្រទេសដែលមានប្រជាជនច្រើនកុះករបំផុតលើពិភពលោក( ទោះបីជាការលើកដាក់តាមផ្លូវទឹកមានការរាំងស្ទះក៏ដោយ )។

**លោក ចាន់ សុខហេង** ដែលជានាយកប្រតិបត្តិរបស់ក្រុមហ៊ុន Signature of Asia Co., ក្រុមហ៊ុននាំចេញអង្ករមួយក្នុងចំណោមក្រុមហ៊ុននាំចេញអង្ករដ៏ទៃទៀតរបស់កម្ពុជា បានសំដែងនូវមោទនៈភាពប្រកបដោយសុទិដ្ឋិនិយមថា ស្ថានភាពនាំចេញអង្កររបស់កម្ពុជាក្នុងឆ្នាំនេះ មានសភាពផុលផុសខ្លាំង ដោយសារគុណភាពអង្ករល្អ និងទំនាក់ទំនងអន្តរជាតិពីមួយថ្ងៃទៅមួយថ្ងៃត្រូវបានលើកកំពស់។

ម៉្យាងទៀត COVID-19 ពុំបានជះឥទ្ធិពលអាក្រក់ដល់សកម្មភាពនាំចេញអង្កររបស់ប្រទេសនេះ។ ប៉ុន្តែកម្ពុជាត្រូវបង្កើនគុណភាពអង្ករ កាត់បន្ថយចំណាយលើការនាំចេញ ស្វែងរកប្រភពទុនវិនិយោគបន្ថែមទៀត ដើម្បីធ្វើការប្រកួតប្រជែងជាមួយប្រទេសនាំចេញដ៏ទៃទៀតក្នុងតំបន់។ បើតាមសេចក្តីប្រកាសរបស់ CRF ក្នុងឆ្នាំ ២០១៩ កម្ពុជានាំចេញអង្ករបានចំនួន ៦២០,១០៦ តោន គឺថយចុះ ០,៩៧% ធៀបទៅនឹងចំនួន ៦២៦,២២៥ តោន ឆ្នាំ ២០១៨។





-តម្លៃទំនិញប្រើប្រាស់ចាំបាច់សំខាន់ៗ លើទីផ្សារអន្តរជាតិ ប្រចាំសប្តាហ៍ទី៣ និងទី៤ ខែមេសា ឆ្នាំ២០២០

**I – អង្ករ៖** ឯកត្តា៖ ដុល្លារ/តោន

| លរ | យថាប្រភេទ | ល័ក្ខខ័ណ្ឌ ប្រគល់-ទទួល | តម្លៃមធ្យម សប្តាហ៍ទី៣ | តម្លៃមធ្យម សប្តាហ៍ទី៤ | កើន(+), ថយ(-) | ភាគរយ (%) |
|---|---|---|---|---|---|---|
| 1 | អង្ករប្រភេទបាក់ ៥% | FOB Bangkok | 502 | 569 | 67 | 13.35 |
| 2 | អង្ករប្រភេទបាក់ ៥% | FOB Vietnam | 428 | 472 | 44 | 10.28 |
| 3 | អង្ករប្រភេទបាក់ ៥% | FOB India | 350 | 350 | 0 | 0.00 |
| 4 | អង្ករប្រភេទបាក់ ៥% | FOB Pakistan | 383 | 452 | 69 | 18.02 |
| 5 | អង្ករប្រភេទបាក់ ៤ % | FOB USA | 583 | 637 | 54 | 9.26 |
| 6 | អង្ករប្រភេទបាក់ ២៥% | FOB Bangkok | 484 | 539 | 55 | 11.36 |
| 7 | អង្ករប្រភេទបាក់ ២៥% | FOB Vietnam | 413 | 447 | 34 | 8.23 |
| 8 | អង្ករប្រភេទបាក់ ២៥% | FOB India | 330 | 330 | 0 | 0.00 |
| 9 | អង្ករប្រភេទបាក់ ២៥% | FOB Pakistan | 343 | 397 | 54 | 15.74 |
| 10 | អង្ករប្រភេទបាក់ ១៥% | FOB USA | 563 | 582 | 19 | 3.37 |
| 11 | អង្ករក្រហមប្រភេទ stxd ១០០% | FOB Bangkok | 564 | 569 | 5 | 0.89 |
| 12 | អង្ករក្រហបប្រភេទ ៥% | FOB Pakistan | 420 | 472 | 52 | 12.38 |
| 13 | អង្ករក្រហបប្រភេទ ៥% | FOB India | 361 | 361 | 0 | 0.00 |
| 14 | អង្ករក្រហបប្រភេទ ៤% | FOB USA | 578 | 597 | 19 | 3.29 |
| 15 | អង្ករក្រអូបHommali 100% | FOB Bangkok | 1072 | 1142 | 70 | 6.53 |
| 16 | អង្ករក្រអូប | FOB Vietnam | 524 | 578 | 54 | 10.31 |
| 17 | អង្ករក្រអូបBasmati 2% | FOB India | 880 | 880 | 0 | 0.00 |
| 18 | អង្ករក្រអូបBasmati 2% | FOB Pakistan | 582 | 582 | 0 | 0.00 |
| 19 | ប្រភេទ ផ្កាមាលីស/រំដួល | FOB Cambodia | 840 | 915 | 75 | 8.93 |

**កំណត់សម្គាល់៖**

-តម្លៃអង្ករលក់ចេញនៅទីផ្សារសំខាន់ៗនៅសប្តាហ៍ទី០១ ខែមេសា ឆ្នាំ២០២០ នេះ គឺមានការប្រែប្រួល ធៀបទៅនឹងសប្តាហ៍ទី០៣។

-នៅសប្តាហ៍ទី០១ នេះ នៅប្រទេសថៃ តម្លៃអង្ករនាំចេញបានកើនឡើង ធៀបទៅនឹងសប្តាហ៍មុន ដោយអង្ករប្រភេទ ១០០% បានកើនឡើង ៥ដុល្លារ/តោន (FOB, Bangkok) គឺលក់ចេញក្នុងតម្លៃជា ៥៦៩ ដុល្លារ/តោន និងប្រភេទ ៥% បានកើន ៦៧ដុល្លារ/តោន លក់ចេញក្នុងតម្លៃ៥៦៩ ដុល្លារ/តោន (FOB, Bangkok) ប្រភេទអង្ករម៉ាលី បានកើន ៧០ដុល្លារ/តោន (FOB, Bangkok) គឺលក់ចេញក្នុងតម្លៃ ១១៤២ដុល្លារ/តោន (FOB, Bangkok) និងប្រភេទ ២៥% កើន៥៥ដុល្លារ/តោន (FOB, Bangkok) ដោយលក់ចេញក្នុងតម្លៃ ៥៣៩ដុល្លារ/តោន (FOB, Bangkok) -និងនៅប៉ាគីស្ថាន តម្លៃអង្ករនាំចេញបានកើនឡើង ធៀបទៅនឹងសប្តាហ៍ទី០៣ ដោយអង្ករប្រភេទ ៥% លក់ចេញក្នុងតម្លៃ ៤៥២ដុល្លារ/តោន (FOB, Pakistan)។ និងប្រភេទ ២៥%

លក់ចេញក្នុងតម្លៃ ៣៩៧ដុល្លារ/តោន (FOB, Pakistan)។ -និងនៅវៀតណាម តម្លៃអង្ករនាំចេញបានកើនឡើងពី ៣៥ ទៅ ៥៤ដុល្លារ/តោន ធៀបសប្តាហ៍ទី០៣ ដោយ ប្រភេទ៥%លក់ក្នុងតម្លៃ៤៧២ដុល្លារ/តោន(FOB,កំពុងផែក្រុងហូជីមិញ) ប្រភេទក្រអូប លក់ចេញក្នុងតម្លៃជាមធ្យម ៥៧៨ដុល្លារ/តោន (FOB, កំពង់ផែក្រុងហូជីមិញ) អង្ករប្រភេទ ២៥%លក់ចេញក្នុងតម្លៃជាមធ្យម ៤៤៧ដុល្លារ/តោន (FOB, កំពង់ផែក្រុងហូជីមិញ)។ នៅសប្តាហ៍នេះ តម្លៃអង្ករនាំចេញនៅលើទីផ្សារអាស៊ីបានកើនថ្លៃខ្ពស់បំផុតធៀបទៅរយៈពេល ៨សប្តាហ៍ទិ០៣ ដោយសាមានសេចក្តីព្រួយបារម្ភអំពីអាកាសធាតុរាំងស្ងួតអូសបន្លាយ ខណៈដែលបរិមាណផលិតផលអង្ករស្តុកឃ្លាំងមានការថយចុះ។

នៅឥណ្ឌា បច្ចុប្បន្ន តម្រូវការអង្កនាំចេញមានការកើនឡើង ប៉ុន្តែប្រភពផ្គត់ផ្គង់បានថយចុះ ដោយសារគោលនយោបាយដាក់ដោយឡែក។ ឈ្មួញនាំចេញអង្កឥណ្ឌា បានផ្អាកចុះកិច្ចសន្យាទិញលក់ក្រោយពីរដ្ឋាភិបាលធ្វើការហាមប្រាម។ ដោយសារគោលនយោបាយដាក់ដោយឡែក ឈានទៅដល់ការខ្វះខាតកំលាំងពលកម្ម ក៏ដូចជាខ្វះកំលាំងលើកដាក់ បានជះឥទ្ធិពលដល់ការប្រគល់ទំនិញទៅតាមកិច្ចសន្យា។ ច្បាប់ឃុំមនុស្សនៅក្នុងផ្ទះមានសុពលភាពដល់ថ្ងៃ ៣ ខែ ឧសភា។ នៅក្នុងប្រទេសជិតខាងឥណ្ឌា គឺបង់ក្លាដេស តម្លៃអង្កបានកើនឡើងខ្ពស់បំផុត បើធៀបទៅនឹងរយៈពេល ២ឆ្នាំមុន ដោយសារឈ្មួញទិញស្តុក។

**II-កសិផលៈ**

| លរ | យថាប្រភេទ | លក្ខខ័ណ្ឌ ប្រគល់-ទទួល | តម្លៃមធ្យម សប្តាហ៍ទី៣ | តម្លៃមធ្យម សប្តាហ៍ទី៤ | កើន(+), ថយ(-) | ភាគរយ (%) |
|---|---|---|---|---|---|---|
| 1 | ស្រូវសាលី (ដុល្លារ/តោន) | FOB Chicago USA | 201.81 | 201.17 | -0.64 | 0.32 |
| 2 | ពោត (ដុល្លារ/តោន) | - | 121.53 | 118.50 | -3.03 | 2.49 |
| 3 | សណ្តែកសៀង (ដុល្លារ/តោន) | - | 314.50 | 307.50 | -7 | 2.23 |
| 4 | សណ្តែកបាយ (ដុល្លារ/តោន) | FOB HCM (VN) | 1,365.00 | 1,350.50 | -14.5 | 1.06 |
| 5 | សណ្តែកដី (ដុល្លារ/តោន) | - | 1,705.00 | 1,720.45 | 15.45 | 0.91 |
| 6 | ល្ងខ្មៅ (ដុល្លារ/តោន) | - | 2,280.00 | 2,305.00 | 25 | 1.10 |
| 7 | ល្ងស (ដុល្លារ/តោន) | - | 2,090.00 | 2,050.00 | -40 | 1.91 |
| 8 | ប្រេងដូងប្រេង (ដុល្លារ/តោន) | FOB Malaysia | 690.00 | 576.54 | -113.46 | 16.44 |
| 9 | ប្រេងសណ្តែកសៀង(ដុល្លារ/តោន) | CIF Rotterdam | 598.50 | 598.50 | 0 | 0.00 |
| 10 | គ្រាប់ម្រេច ខ្មៅ (ដុល្លារ/តោន) | FOB (V.N) | 2,190.00 | 1,950.00 | -240 | 10.96 |
| 11 | គ្រាប់ម្រេច ស (ដុល្លារ/តោន) | - | 2,850.00 | 2,720.00 | -130 | 4.56 |
| 12 | គ្រាប់ស្វាយចន្ទីកែច្នៃរួច (ដុល្លារ/តោន) | FOB HCM (VN) | 5,475.00 | 4,950.00 | -525 | 9.59 |
| 13 | មើមខ្ទឹមស (ដុល្លារ/តោន) | FOB HCM (VN) | 505 | 505 | 0 | 0.00 |
| 14 | មើមខ្ទឹមក្រហម (ដុល្លារ/តោន) | FOB HCM (VN) | 470 | 470 | 0 | 0.00 |
| 15 | ស្លឹកតែBT(ដុល្លារ/គីឡូក្រាម) | - | 2.95 | 2.95 | 0 | 0.00 |
| 16 | មើមក្រាវ (ដុល្លារ/តោន) | FOB HCM (VN) | 1,313.00 | 1,201.00 | -112 | 8.53 |
| 17 | កាហ្វេ (ROBUSTA) (ដុល្លារ/តោន) | FOB HCM (VN) | 1,206.00 | 1,084.00 | -122 | 10.12 |
| 18 | កាហ្វេ (ROBUSTA) (ដុល្លារ/តោន) | FOB New York (USA) | 2,530.00 | 2,445.00 | -85 | 3.36 |
| 19 | កាហ្វេ (ARABICA) (ដុល្លារ/តោន) | London | 1,122.57 | 1,370.50 | 247.93 | 22.09 |
| 20 | កប្បាសលេខ ២ (ដុល្លារ/តោន) | FOB New York | 2,260.00 | 2,258.00 | -2 | 0.09 |
| 21 | កាការ (ដុល្លារ/តោន) | CIF New York (USA) | 201.81 | 201.17 | -0.64 | 0.32 |
| 22 | ផ្លែស្រកានាគ (ដុល្លារ/តោន) | - | 121.53 | 118.50 | -3.03 | 2.49 |

**កំណត់សម្គាល់**៖ តម្លៃកសិផលគ្រប់ប្រភេទមានការប្រែប្រួលទៅតាមប្រភេទ នីមួយៗ នៅសប្តាហ៍ទី០៤។

**-តម្លៃពោត**៖ តម្លៃពោតនាំចេញនៅ Chicago បានថយចុះ ៣,០៣ដុល្លារ/តោន (២,៤៩%) ធៀបសប្តាហ៍ទី០៣ ដោយលក់ចេញក្នុងតម្លៃ ១១៨,៥០ ដុល្លារ/តោន (FOB, Chicago)។

**-តម្លៃស្រូវសាលី**៖ តម្លៃស្រូវសាលីនាំចេញនៅ Chicago បានថយ ០,៦៤ដុល្លារ/តោន (០,៣២%) ធៀបសប្តាហ៍ទី០៣ ដោយលក់ចេញក្នុងតម្លៃ ២០១,១៧ដុល្លារ/តោន (FOB Chicago)។

**-តម្លៃសណ្តែកបាយ**៖ តម្លៃសណ្តែកបាយនាំចេញ បានថយចុះ១៤,៥០ដុល្លារ/តោន (១,០៦%) ធៀបសប្តាហ៍ទី០៣ ដោយលក់ចេញក្នុងតម្លៃ ១,៣៥០.00ដុល្លារ/តោន (FOB, កំពង់ផែក្រុងហូជីមីញ)។

**-តម្លៃសណ្តែកដី**៖ នៅសប្តាហ៍ទី០៤ តម្លៃសណ្តែកដីនាំចេញបានកើនឡើង ១៥,៤៥ ដុល្លារ/តោន (០,៩១%) ធៀបសប្តាហ៍ទី០៣ ដោយលក់ចេញក្នុងតម្លៃ ១.៧២០,៤៥ ដុល្លារ/តោន(FOB, កំពង់ផែក្រុងហូជីមីញ)។

**-តម្លៃសណ្តែកសៀង**៖ នៅ Chicago តម្លៃសណ្តែកសៀងនាំចេញបានថយ ៧,០០ដុល្លារ/តោន (២,២៣%) ធៀបទៅនឹងសប្តាហ៍ទី០៣ដោយលក់ចេញក្នុងតម្លៃ៣០៧,៥០ ដុល្លារ/តោន,FOB Chicago ។

**-តម្លៃប្រេងដូងប្រេង**៖ តម្លៃប្រេងដូងប្រេងនៅទីផ្សារប្រទេសម៉ាឡេស៊ី ១១៣,៤៦ដុល្លារ/តោន (១៦,៤៤%) មានស្ថេរភាពធៀបសប្តាហ៍ទី០៣ ដោយលក់ចេញក្នុងតម្លៃ ៥៧៦,៥៤ ដុល្លារ/តោន (FOB, Malaysia )។

**-តម្លៃកាហ្វេ**៖ តម្លៃកាហ្វេនាំចេញនៅលើទីផ្សារសំខាន់ៗ បានថយចុះធៀបទៅនឹងសប្តាហ៍ទី០៣។ នៅទីផ្សារ New York តម្លៃកាហ្វេរ៉ូប៊ូស្តារលក់ចេញបានថយ១២២,00 ដុល្លារ/តោន (១០,១២%) ដោយលក់ក្នុងតម្លៃ១.០៨៤,00 ដុល្លារ/តោន, FOB (ទីផ្សារ New York) និងនៅទីផ្សារអាស៊ីតម្លៃកាហ្វេរ៉ូប៊ូស្តា របស់វៀតណាមបានថយ១១២,00 ដុល្លារ/តោន(៨,៥៣%)ដោយលក់ចេញក្នុងតម្លៃ១,២០១.00 ដុល្លា/តោន (FOB, កំពង់ក្រុងហូជីមីញ) និងនៅក្រុងឡុងដ៏ តម្លៃកាហ្វេអារ៉ាប៊ីកាលក់ចេញបានថយ ៨៥,០០ដុល្លារ/តោន(៣,៣៦%) ដោយលក់ចេញក្នុងតម្លៃ ២,៤៤៥.00 ដុល្លារ/តោន(FOB, កំពង់ផែក្រុងឡុងដ៏) ដោយសារតម្រូវការថយចុះពីសំណាក់អ្នកប្រើប្រាស់ ស្របពេលដែលសណ្ឋាគា ផ្ទះសំណាក់ ភោជនីយដ្ឋាន បានបិទទ្វារ។

**III-ផលិតផលនេសាទ៖**

| លរ | យថាប្រភេទ | លក្ខខ័ណ្ឌ ប្រគល់-ទទួល | តម្លៃមធ្យម សប្តាហ៍ទី៣ | តម្លៃមធ្យម សប្តាហ៍ទី៤ | កើន(+), ថយ(-) | ភាគរយ (%) |
|---|---|---|---|---|---|---|
| 1 | បង្គាស្រស់ខ្នាតនាំចេញ(១០ទៅ១៥ក្បាល/គក) (ដុល្លារ/តោន) | FOB HCM (VN) | 6,700 | 6,600 | -100 | 1.49 |
| 2 | បង្គាស្រស់ខ្នាតនាំចេញ (៣០ក្បាល/គក) (ដុល្លារ/តោន) | FOB HCM (VN) | 4,400 | 4,350 | -50 | 1.14 |
| 3 | មឹកបង្កក (២០ក្បាល/គក ) (ដុល្លារ/តោន) | - | 3,500 | 3,400 | -100 | 2.86 |

**IV-ផលិតផលឧស្សាហកម្ម៖**

| លរ | យថាប្រភេទ | លក្ខខ័ណ្ឌ ប្រគល់-ទទួល | តម្លៃមធ្យម សប្តាហ៍ទី៣ | តម្លៃមធ្យម សប្តាហ៍ទី៤ | កើន(+), ថយ(-) | ភាគរយ (%) |
|---|---|---|---|---|---|---|
| 1 | ស្ករស(ដុល្លារ/តោន) | CIF London | 327.15 | 324.60 | -2.55 | 0.78 |
| 2 | ស្ករមិនទាន់កែច្នៃ(ដុល្លារ/តោន) | - | 240.24 | 253.78 | 13.54 | 5.64 |
| 3 | ស្ករស(ដុល្លារ/តោន) | FOB HCM (VN) | 625.00 | 625.00 | 0 | 0.00 |

| | | | | | | |
|---|---|---|---|---|---|---|
| 4 | កៅស៊ូប្រភេទលេខ១(ដុល្លារ/តោន) | - | 1,320.00 | 1,370.00 | 50 | 3.79 |
| 5 | កៅស៊ូប្រភេទលេខ ២(ដុល្លារ/តោន) | - | 1,300.00 | 1,350.00 | 50 | 3.85 |
| 6 | កៅស៊ូប្រភេទ RSS1(ដុល្លារ/តោន) | FOB Bangkok | 1,350.00 | 1,350.00 | 0 | 0.00 |
| 7 | កៅស៊ូប្រភេទ RSS3(ដុល្លារ/តោន) | FOB Sang hai | 1,401.00 | 1,421.00 | 20 | 1.43 |
| 8 | កៅស៊ូប្រភេទ RSS2(ដុល្លារ/តោន) | FOB Singapore | 1,206.00 | 1,250.00 | 44 | 3.65 |
| 9 | កៅស៊ូប្រភេទ RSS3(ដុល្លារ/តោន) | FOB Tokyo | 1,339.95 | 1,430.00 | 90.05 | 6.72 |
| 10 | កៅស៊ូប្រភេទ SMRCV(ដុល្លារ/តោន) | FOB Malaysia | 1,190.00 | 1,250.00 | 60 | 5.04 |
| 11 | កៅស៊ូប្រភេទ SIR 20(ដុល្លារ/តោន) | FOB Indonesia | 1,200.00 | 1,230.00 | 30 | 2.50 |

**កំណត់សម្គាល់៖**
តម្លៃទំនិញឧស្សាហកម្មមានការប្រែប្រួលទៅតាមប្រភេទនីមួយៗ ពិសេសតម្លៃស្ករស និងតម្លៃកៅស៊ូធម្មជាតិនៅសប្តាហ៍ទី០៤។

**-តម្លៃស្ករស៖** នៅទីផ្សារឡុងដ៍ តម្លៃស្ករសលក់ចេញបានថយចុះ ២,៥៥ដុល្លារ/តោន(០,៧៨%)ធៀបទៅនឹងសប្តាហ៍ទី០៣ ដោយលក់ចេញក្នុងតម្លៃ ៣២៤,៦០ ដុល្លារ/តោន (FOB, ឡុងដុង) ដោយសារតម្លៃប្រេងឆៅថយចុះ ។

**-កៅស៊ូធម្មជាតិ៖** តម្លៃកៅស៊ូធម្មជាតិប្រភេទ RSS2 លក់ចេញនៅទីផ្សារតូក្យូប្រទេសជប៉ុននៅសប្តាហ៍ទី០៤ បានកើនឡើង ៩០,០៥ដុល្លារ/តោន (៦,៧២%) ធៀបទៅនឹងសប្តាហ៍ទី០៣ ដោយលក់ចេញក្នុងតម្លៃ ១.៤៣០,០០ ដុល្លារ/តោន (FOB ,Tokyo) ក្រោយប្រធានាធិបតីអាមេរិក Donald Trump ប្រកាសអំពីផែនការ បើកទ្វារខឿនសេដ្ឋកិច្ចឡើងវិញ។

## V-ឥន្ធនៈ៖

| លរ | យថាប្រភេទ | ល័ក្ខខ័ណ្ឌ ប្រគល់-ទទួល | តម្លៃមធ្យម សប្តាហ៍ទី៣ | តម្លៃមធ្យម សប្តាហ៍ទី៤ | កើន(+), ថយ(-) | ភាគរយ (%) |
|---|---|---|---|---|---|---|
| 1 | ប្រេងឆៅ Brent ($/ធុង) | FOB (New York) | 34.11 | 25.57 | -8.54 | 25.04 |
| 2 | ប្រេង WTI ($/ធុង) | - | 28.34 | 23.39 | -4.95 | 17.47 |
| 3 | ហ្គាស ( Gas)(ដុល្លារ/តោន) | F0B (VN) | 297.00 | 261.75 | -35.25 | 11.87 |

**កំណត់សម្គាល់៖** នៅសប្តាហ៍នេះ ទំនិញប្រេងឥន្ធនៈមានការប្រែប្រួលទៅតាមប្រភេទនីមួយៗ និងជាពិសេសតម្លៃប្រេងឆៅ។

**-តម្លៃប្រេងឆៅ (Brent)៖** នៅទីផ្សារក្រុងឡុងដ៍តម្លៃប្រេងឆៅ Brent បានថយចុះ ៨,៥៤ដុល្លារ/ធុង (២៥,០៤%) ដោយលក់ចេញក្នុងតម្លៃ ២៥,៥៧ ដុល្លារ/ធុង (FOB London)។ ក្រោយពីអ្នកវិនិយោគមានការព្រួយបារម្ភអំពីប្រភពផ្គត់ផ្គង់មានការកើនឡើង ស្របពេលដែលតម្រូវការធ្លាក់ចុះ និង ខ្វះកន្លែងរក្សាទុក។

## VI-លោហៈ៖

| លរ | យថាប្រភេទ | ល័ក្ខខ័ណ្ឌ ប្រគល់-ទទួល | តម្លៃមធ្យម សប្តាហ៍ទី៣ | តម្លៃមធ្យម សប្តាហ៍ទី៤ | កើន(+), ថយ(-) | ភាគរយ (%) |
|---|---|---|---|---|---|---|
| 1 | មាស ( $ / ounce ) | Hong Kong | 1,645.70 | 1,707.50 | 61.8 | 3.76 |
| 2 | មាស ( $ / ounce ) | London | 1,649.00 | 1,711.00 | 62 | 3.76 |

| | | | | | | |
|---|---|---|---|---|---|---|
| 3 | មាស ( $ / ounce ) | New York | 1,655.00 | 1,705.00 | 50 | 3.02 |
| 4 | Platinum ($ / ounce) | - | 725.13 | 774.85 | 49.72 | 6.86 |
| 5 | មាស ( $ / ounce ) | Dubai | 1,655.50 | 1,718.00 | 62.5 | 3.78 |
| 6 | មាស ( Jpy / Gram ) | Tokyo | 5,640.00 | 5,850.00 | 210 | 3.72% |
| 7 | មាស ( $ / ounce ) | Zurich | 1,651.50 | 1,715.50 | 64 | 3.88 |
| 8 | Palladium ( $ / ounce ) | New York | 2,164.10 | 2,177.39 | 13.29 | 0.61 |
| 9 | ប្រាក់ ( $/troy ounce ) | London | 14.49 | 15.65 | 1.16 | 8.01 |
| 10 | ប្រាក់ ( $/troy ounce ) | New York | 14.00 | 15.10 | 1.1 | 7.86 |
| 11 | ស្ពាន់( ដុល្លារ/តោន ) | FOB (London) | 4,839.00 | 5,211.00 | 372 | 7.69 |
| 12 | អាលុយមីញ៉ូម (Al) (ដុល្លារ/តោន) | - | 1,595.00 | 1,507.00 | -88 | 5.52 |
| 13 | ស័ង្កសី (Zinc ) (ដុល្លា/តោន ) | - | 1,882.00 | 1,958.00 | 76 | 4.04 |
| 14 | សំណប៉ាហាំង (Tin) (ដុល្លារ/តោន) | - | 14,123 | 15,070 | 947 | 6.71 |
| 15 | នីកែល (Nickel) (ដុល្លារ/តោន ) | - | 11,162.00 | 11,846.23 | 684.23 | 6.13 |
| 16 | ដែកថែបមូលអង្កត់ផ្ចិត០.៤មម | - | 455 | 455 | 0 | 0.00 |

**<u>កំណត់សម្គាល់</u>**៖ តម្លៃទំនិញលោហៈ មានការប្រែប្រួលទៅតាមប្រភេទនីមួយៗ ជាពិសេសតម្លៃមាស។ នៅលើទីផ្សារអន្តរជាតិ តម្លៃមាសមានការប្រែប្រួល ធៀបទៅនឹងសប្តាហ៍ទី០៣ នៅទីក្រុងឡុងដ៍តម្លៃមាសលក់ចេញបានកើនឡើង ៦២,០០ដុល្លារ/Ounce (៣,៧៦%) ដោយលក់ចេញក្នុងតម្លៃ ១.៧១១,០០ USD/Ounce និងនៅហុងកុង តម្លៃមាសលក់ចេញកើន ៦១,៨០ដុល្លារ/ធុង (៣,៧៦%) ដោយលក់ចេញក្នុងតម្លៃ ១.៧០៧,៥០ USD/Ounce។

**VII-អត្រាប្តូរប្រាក់៖**

| លរ | យថាប្រភេទ | ល័ក្ខខ័ណ្ឌ ប្រគល់-ទទួល | តម្លៃមធ្យម សប្តាហ៍ទី៣ | តម្លៃមធ្យម សប្តាហ៍ទី៤ | កើន(+), ថយ(-) | ភាគរយ (%) |
|---|---|---|---|---|---|---|
| 1 | ដុល្លារអាមេរិក USD / EUR) | London | 0.9200 | 0.9230 | 0.003 | 0.33 |
| 2 | យ៉េនជប៉ុន ( USD/JPY) | Tokyo | 108.81 | 107.36 | -1.45 | 1.33 |
| 3 | ហ្វ្រង់ស្វីស (CHF/USD) | New York | 1.0292 | 1.0306 | 0.0014 | 0.14 |
| 4 | ផោនអង់គ្លេស ( GBP/USD) | London | 1.2322 | 1.2388 | 0.0066 | 0.54 |
| 5 | រាំងគិតម៉ាឡេស៊ី ( USD/MYR) | Kualalumpur | 4.3415 | 4.3925 | 0.051 | 1.17 |
| 6 | ដុល្លារហុងកុង( USD/HKD) | Hong Kong | 7.7520 | 7.7501 | -0.0019 | 0.02 |
| 7 | បាតថៃ ( USD/THB) | Bangkok | 32.4640 | 32.8420 | 0.378 | 1.16 |
| 8 | ដុល្លារសឹង្ហបុរី (USD/ SGD) | Singapore | 1.4272 | 1.4275 | 0.0003 | 0.02 |
| 9 | ដុងវៀតណាម ( USD/VND) | HCM | 23,463.80 | 23,461 | -2.8 | 0.01 |

| | | | | | | |
|---|---|---|---|---|---|---|
| 10 | Yuan ចិន (USD/ CNY) | Peking | 7.0634 | 7.0840 | 0.0206 | 0.29 |
| 11 | Rupiah ឥណ្ឌូនេស៊ី ( USD/IDR) | Jakarta | 16.205 | 15.467 | -0.738 | 4.55 |
| 12 | ដុល្លារអូស្ត្រាលី )USD/AUD) | Canberra | 1.6295 | 1.5872 | -0.0423 | 2.60 |
| 13 | Rupi ឥណ្ឌា )USD/INR) | Newdelhi | 75.6300 | 76.8338 | 1.2038 | 1.59 |
| 14 | Won កូរ៉េ) USD/KRW) | Seoul | 1,220.25 | 1,229.66 | 9.41 | 0.77 |

**កំណត់សម្គាល់**៖ អត្រាប្តូរប្រាក់នៅតាមទីផ្សារសំខាន់ៗ មានការប្រែប្រួលជាពិសេសតម្លៃប្រាក់ដុល្លារអាមេរិក ធៀបទៅនឹងប្រាក់អឺរ៉ូនៅសប្តាហ៍ទី០៤។

**-តម្លៃរូបិយបណ្ណ័**៖ តម្លៃប្រាក់ដុល្លារអាមេរិកធៀបទៅនឹងប្រាក់អឺរ៉ូ បានកើន០,០០៣ អឺរ៉ូ/ដុល្លារ (០,៣៣%) ធៀបទៅនឹងសប្តាហ៍មុន គឺលក់ចេញក្នុងតម្លៃ០.៩២៣០អឺរ៉ូ/ដុល្លារ និងប្រាក់យ៉េនជប៉ុនកើន ១,៤៥យ៉េន/ដុល្លារ (១,៣៣%) ធៀបសប្តាហ៍ទី០៣ ដោយលក់ចេញក្នុងតម្លៃ ១០៧,៣៦យ៉េន/ដុល្លារ។

(គ្រប់តារាងទំនិញប្រើប្រាស់ចាំបាច់សំខាន់ៗលើទីផ្សារអន្តរជាតិប្រចាំសប្តាហ៍បកប្រែនិងសម្រួលតាមច្បាប់ដើមពីកាសែតបរទេសដោយនាយកដ្ឋានផែនការស្ថិតិ និងព័ត៌មានពាណិជ្ជកម្ម)






# ច្បាប់

## ស្ដីពី

# វិនិយោគ
# នៃព្រះរាជាណាចក្រកម្ពុជា

# ព្រះរាជក្រម

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធិពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

យោងតាមមាត្រាទី ១១ ជំពូកទី ២ ស្តីអំពី ព្រះមហាក្សត្រ នៃ រដ្ឋធម្មនុញ្ញព្រះរាជាណាចក្រ កម្ពុជា ដែលត្រូវបានសភាធម្មនុញ្ញអនុម័ត នៅ ថ្ងៃទី ២១ ខែកញ្ញា ឆ្នាំ១៩៩៣

## បង្គាប់

**មាត្រា ១.** ប្រកាសអោយប្រើជាផ្លូវការ នូវច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា ដែលរដ្ឋសភា បានអនុម័តនៅថ្ងៃទី ០៤ ខែសីហា ឆ្នាំ១៩៩៤ ។

**មាត្រា ២.** ព្រះរាជក្រមនេះចូលជាធរមានច្បាប់ ចាប់ពីពេលចុះហត្ថលេខានេះតទៅ ។

ធ្វើនៅព្រះរាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែសីហា ឆ្នាំ១៩៩៤

ក្នុងព្រះបរមនាម និង ដោយព្រះរាជបង្គាប់

ប្រមុខរដ្ឋស្តីទី

# ច្បាប់

## ស្តីពី
## វិនិយោគ
## នៃព្រះរាជាណាចក្រកម្ពុជា

### ជំពូកទី ១
### បទបញ្ញត្តិទូទៅ

មាត្រា ១.-

ច្បាប់នេះមានវិសាលភាពគ្របដណ្តប់លើការវិនិយោគនានា ដែលអនុវត្តនៅលើទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ដោយអ្នកវិនិយោគជាជនជាតិខ្មែរនិង / ឬ ជនបរទេស ។

មាត្រា ២.-

អ្នកវិនិយោគទាំងអស់ត្រូវស្ថិតនៅក្រោមច្បាប់នេះ ហើយអាចជារូបវន្តបុគ្គលឬជានីតិបុគ្គល ។

### ជំពូកទី ២
### ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

មាត្រា ៣.-

ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ជាអង្គការមានសមត្ថកិច្ច និងជាច្រកចេញចូលតែមួយគត់ក្នុងការទទួលបន្ទុកការងារនីតិសម្បទា អភិវឌ្ឍន៍និងការវិនិយោគ ។ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ជាសេនាធិការរបស់រាជរដ្ឋាភិបាល ក្នុងការពិនិត្យនិងសំរេចការងារនីតិសម្បទានិងអភិវឌ្ឍន៍ និងការវិនិយោគនានា ។

មាត្រា ៤._

ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា មានគណៈកម្មាធិការពីរសំរាប់ជំនួយការគឺ ៖

១_ គណៈកម្មាធិការនីតិសម្បទា និង អភិវឌ្ឍន៍

២_ គណៈកម្មាធិការវិនិយោគកម្ពុជា ។

មាត្រា ៥._

ការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ត្រូវកំណត់ដោយអនុក្រឹត្យ ។

## ជំពូកទី ៣
## នីតិវិធីនៃការវិនិយោគ

មាត្រា ៦._

អ្នកវិនិយោគត្រូវដាក់ពាក្យសុំទៅក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាដើម្បីពិនិត្យ និងសំរេច ។

មាត្រា ៧._

ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ត្រូវឆ្លើយតបអំពីការសំរេចរបស់ខ្លួនទៅអ្នកវិនិយោគ ក្នុងរយៈពេល ៤៥ ថ្ងៃយ៉ាងយូរ គិតពីថ្ងៃទទួលពាក្យសុំដែលបានបំពេញបែបបទត្រឹមត្រូវនិងគ្រប់គ្រាន់ ។ បើគ្មានមូលហេតុត្រឹមត្រូវ មន្ត្រីរាជការណាដែលប្រកែកមិនព្រមទទួលពិនិត្យនិងឆ្លើយតបអំពីការសំរេចរបស់ខ្លួនទៅអ្នកវិនិយោគវិញ ហួសកាលកំណត់ខាងលើ ត្រូវផ្តន្ទាទោសតាមបញ្ញត្តិច្បាប់ ។

## ជំពូកទី ៤
## ការធានាលើការវិនិយោគ

មាត្រា ៨._

អ្នកវិនិយោគត្រូវបានទទួលស្គាល់និងចាត់ទុកដោយស្មើភាពគ្នាចំពោះមុខច្បាប់ គ្មានការរើសអើងអំពីសញ្ជាតិឬពូជសាសន៍ទេ លើកលែងតែចំពោះកម្មសិទ្ធិលើដីធ្លី ដូចដែលមានចែងក្នុងបទបញ្ញត្តិនៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ។

មាត្រា ៩._

រាជរដ្ឋាភិបាលនឹងមិនធ្វើជាតូបនីយកម្ម ដែលនាំឱ្យប៉ះពាល់ដល់ទ្រព្យសម្បត្តិរបស់អ្នកវិនិយោគក្នុងព្រះរាជាណាចក្រកម្ពុជាឡើយ ។

មាត្រា ១០._

រាជរដ្ឋាភិបាលមិនត្រួតពិនិត្យលើថ្លៃផលិតផលឬថ្លៃសេវានានារបស់អ្នកវិនិយោគ ដែលបានទទួលការអនុញ្ញាតរួចហើយនោះឡើយ ។

មាត្រា ១១._

ដោយអនុលោមទៅតាមច្បាប់ទាំងឡាយដែលពាក់ព័ន្ធ ព្រមទាំងបទបញ្ញត្តិទាំងឡាយដែលបានកំណត់និងប្រកាសផ្សាយដោយធនាគារជាតិកម្ពុជា រាជរដ្ឋាភិបាលអនុញ្ញាតដល់អ្នកវិយោគ មានសិទ្ធិទិញរូបិយប័ណ្ណបរទេសតាមរយៈប្រព័ន្ធធនាគារ សំរាប់បង្វិលទៅបរទេសវិញ ដើម្បីទូទាត់កាតព្វកិច្ចខាងហិរញ្ញវត្ថុដែលពាក់ព័ន្ធនឹងការវិនិយោគរបស់ខ្លួន ។

ការទូទាត់ខាងលើនេះរួមមាន ៖

១_ ការទូទាត់លើការនាំចូល និងការបង្វិលទៅក្រៅប្រទេសទាំងដើមទាំងការប្រាក់ចងការ ។

២_ ការទូទាត់ចំណាយសួយសារ និង ថ្លៃសេវាគ្រប់គ្រង ។

៣_ ការផ្ទេរប្រាក់ចំណេញ ។

៤_ ការបង្វិលដើមទុនវិនិយោគទៅក្រៅប្រទេសវិញ ដូចមានចែងក្នុងជំពូកទី ៨ ។

## ជំពូកទី ៥
## ការលើកទឹកចិត្តវិនិយោគ

មាត្រា ១២._

រាជរដ្ឋាភិបាលលើកទឹកចិត្ត ដើម្បីជំរុញការវិនិយោគលើវិស័យសំខាន់ៗដូចតទៅ ៖

១_ ឧស្សាហកម្មនាំមុខ ឬ ឧស្សាហកម្មដែលមានបច្ចេកវិទ្យាខ្ពស់

២_ ការបង្កើតការងារ

៣- ការបង្កើនការនាំចេញ

៤- ឧស្សាហកម្មទេសចរណ៍

៥- ការផលិតទំនិញកសិ-ឧស្សាហកម្ម និង ឧស្សាហកម្មកែច្នៃ

៦- ការកសាងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និង ការផលិតថាមពល

៧- អភិវឌ្ឍន៍ខេត្ត និងជនបទ

៨- ការការពារបរិស្ថាន

៩- ការវិនិយោគក្នុងតំបន់អភិវឌ្ឍន៍ពិសេស ដែលនឹងត្រូវបង្កើតឡើងដោយច្បាប់ ។

មាត្រា ១៣.-

ការលើកទឹកចិត្តមាន ការលើកលែងទាំងស្រុង ឬមួយផ្នែកនៃពន្ធគយនិងពន្ធអាករ ។

មាត្រា ១៤.-

ការលើកទឹកចិត្តទាំងឡាយ រួមមានដូចខាងក្រោមនេះ ៖

១- អត្រាពន្ធលើប្រាក់ចំណេញសុទ្ធ ៩% លើកលែងតែអត្រាពន្ធផ្សេងៗលើការរុករក និង អាជីវកម្មធនធានធម្មជាតិ ព្រៃឈើ ប្រេងកាត ជ័ មាស ត្បូងថ្មមានតម្លៃ ។ ល ។ ដែលត្រូវចែងក្នុងច្បាប់ដោយឡែក ។

២- ពន្ធលើប្រាក់ចំណេញអាចលើកលែងបានរហូតដល់រយៈពេល ៨ ឆ្នាំ គឺអាស្រ័យលើលក្ខណៈសម្បត្តិរបស់ការវិនិយោគនីមួយៗនិងអាទិភាព ដែលរាជរដ្ឋាភិបាលនឹងកំណត់ដោយអនុក្រិត្យ ។ ការលើកលែងពន្ធលើប្រាក់ចំណេញនឹងត្រូវអនុវត្តចាប់ពីឆ្នាំដែលបានទទួលប្រាក់ចំណេញលើកទីមួយ ។ ការខាតបង់រយៈពេល ៥ ឆ្នាំបន្តបន្ទាប់ ត្រូវបានអនុញ្ញាតឱ្យយកមកទូទាត់គិតប្រាក់ចំណេញ ។ ក្នុងករណីយកប្រាក់ចំណេញមកធ្វើវិនិយោគបន្ត ប្រាក់ចំណេញត្រូវបានអនុញ្ញាតឱ្យរួចពន្ធទាំងស្រុង ។

៣- មិនយកអាករលើការបែងចែកប្រាក់ចំណេញនៃការវិនិយោគ ទោះជាប្រាក់ទាំងនោះត្រូវផ្ទេរទៅបរទេសក្តី ឬបែងចែកក្នុងប្រទេសក្តី ។

៤- ការលើកលែងពន្ធគយ និងពន្ធអាករ ១០០% ក្នុងការនាំចូលសម្ភារៈសំណង់ មធ្យោបាយផលិតកម្ម គ្រឿងសម្ភារៈបរិក្ខារ ទំនិញពាក់កណ្តាលសំរេច វត្ថុធាតុដើម និងគ្រឿងបន្លាស់សំរាប់ប្រើប្រាស់ ត្រូវមានលក្ខខ័ណ្ឌណាមួយដូចតទៅ ៖

ក- ការវិនិយោគដែលមានទិសដៅសំរាប់បំរើឱ្យការនាំចេញ ក្នុងកំរិតអប្បបរមា ៨០% នៃផលិតផលសរុប ។

ខ- មានទីតាំងនៅក្នុងតំបន់អភិវឌ្ឍន៍ពិសេស ដែលមានក្នុងបញ្ជីអាទិភាពសំរាប់អភិវឌ្ឍន៍ប្រកាសដោយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ។

គ_ ឧស្សាហកម្មទេសចរណ៍

ឃ_ ឧស្សាហកម្មប្រើប្រាស់កម្លាំងពលកម្មច្រើន ឧស្សាហកម្មកែច្នៃ កសិ_ឧស្សាហកម្ម ។

ង_ ការកសាងហេដ្ឋារចនាសម្ព័ន្ធរូបវន្តនិងការផលិតថាមពល ។

ការលើកលែងពន្ធគយ និងពន្ធអាករ ១០០% ខាងលើនេះ ត្រូវអនុវត្តជាប្រចាំ រហូតស្របតាមរយៈពេលដែលកំណត់ក្នុងកិច្ចសន្យា ឬ សៀវភៅបន្ទុក សំរាប់ការវិនិ_យោគដែលផលិតទំនិញនាំចេញក្នុងកំរិតអប្បបរមា ៨០% នៃផលិតកម្មសរុប ដូចមានចែងក្នុងចំណុច (៤)ក ខាងលើ និងសំរាប់ការវិនិយោគដែលមានទីតាំងក្នុងតំបន់អភិវឌ្ឍន៍ពិសេស ដូចមានចែងក្នុងចំណុច (៤)ខ ។

ក្រៅពីប្រភេទការវិនិយោគដែលមានចែងក្នុងចំណុច(៤)ក និងចំណុច (៤)ខ ខាងលើនេះ ការលើកលែងពន្ធគយ និង ពន្ធអាករ ១០០% ត្រូវបានអនុញ្ញាតឱ្យសំរាប់តែក្នុងរយៈពេលនៃការរៀបចំកសាងសហគ្រាស រោងចក្រ អាគារនិងការចាប់ដំណើរការអាជីវកម្ម ផលិតកម្មនៅឆ្នាំដំបូងប៉ុណ្ណោះ ។

៥_ ការលើកលែងពន្ធគយ ១០០% ក្នុងការនាំចេញផលិតផលទៅក្រៅប្រទេស ។

៦_ ការអនុញ្ញាតឱ្យយកចូលមកក្នុងព្រះរាជាណាចក្រកម្ពុជានូវជនបរទេសណាដែលជា ៖

- បុគ្គលិក និង អ្នកជំនាញការខាងគ្រប់គ្រង
- បុគ្គលិកបច្ចេកទេស
- កម្មករជំនាញ
- សហព័ទ្ធនិងអ្នកក្នុងបន្ទុករបស់ខ្លួន ដែលអនុញ្ញាតដោយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ហើយស្របទៅតាមច្បាប់អន្តោប្រវេសន៍និងច្បាប់ការងារ ។

មាត្រា ១៥._

ការអនុញ្ញាតនិងការលើកទឹកចិត្តដែលបានផ្តល់ដោយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាមិនអាចផ្ទេរ ឬ លក់បានឡើយ ។

## ជំពូកទី ៦
## កម្មសិទ្ធិ និង ការប្រើប្រាស់ដីធ្លី

មាត្រា ១៦._

អនុលោមតាមរដ្ឋធម្មនុញ្ញ ច្បាប់និងបទបញ្ញត្តិទាំងឡាយ ដែលពាក់ព័ន្ធទៅនឹងកម្មសិទ្ធិ និងការប្រើប្រាស់ដីធ្លី ៖

១- កម្មសិទ្ធិលើដីធ្លីសំរាប់បំរើឱ្យគោលដៅនៃសកម្មភាពវិនិយោគ ត្រូវបានប្រគល់ជូនចំពោះអ្នកវិនិយោគដែលជារូបវន្តបុគ្គល ឬនីតិបុគ្គលដែលមានសញ្ជាតិជាខ្មែរ ។ នីតិបុគ្គលមានសញ្ជាតិជាខ្មែរ គឺជានីតិបុគ្គលដែលភាគហ៊ុនចាប់តាំងពី ៥១% ឡើងទៅនៃដើមទុនសរុបជាកម្មសិទ្ធិនៃរូបវន្តបុគ្គល ឬ នីតិបុគ្គលដែលមានសញ្ជាតិជាខ្មែរ ។

២- អ្នកវិនិយោគអាចប្រើប្រាស់ដីធ្លីតាមរយៈការជួលសំរាប់រយៈពេលវែងរហូតដល់ ៧០ ឆ្នាំ ហើយអាចស្នើសុំជួលបន្ត ។ ការប្រើប្រាស់ដីធ្លីនេះ រាប់បញ្ចូលទាំងសិទ្ធិនៃកម្មសិទ្ធិទាំងឡាយនៅលើផ្ទៃដីនោះ ត្រូវអនុវត្តស្របតាមច្បាប់ ។

## ជំពូកទី ៧
## ការប្រើប្រាស់កំលាំងពលកម្ម

### មាត្រា ១៧.-

អ្នកវិនិយោគនៅព្រះរាជាណាចក្រកម្ពុជា មានសិទ្ធិធ្វើការជ្រើសរើស និងជួលនិយោជិតខ្មែរ និង បរទេសបានដោយសេរី ផ្អែកលើមូលដ្ឋាននៃច្បាប់ការងារ និង ច្បាប់អន្តោប្រវេសន៍ ។

### មាត្រា ១៨.-

អ្នកវិនិយោគត្រូវបានអនុញ្ញាតឱ្យជួលនិយោជិតបរទេស ដូចមានចែងក្នុងមាត្រា១៤ (៦) ក្នុងលក្ខខ័ណ្ឌដូចតទៅ ៖

១- គុណភាព សមត្ថភាព និងជំនាញមិនអាចរកបាននៅព្រះរាជាណាចក្រកម្ពុជាក្នុងចំណោមប្រជាពលរដ្ឋខ្មែរ ។ បើមានការជួលនិយោជិតប្រភេទនេះ ត្រូវភ្ជាប់មកជាមួយនូវសេចក្តីចម្លងលិខិតឆ្លងដែន សញ្ញាប័ត្រ និងប្រវត្តិរូបសង្ខេបរបស់និយោជិតនោះ ។

២- អ្នកវិនិយោគមានកាតព្វកិច្ចធ្វើការបណ្តុះបណ្តាលជាប្រចាំ និងសមស្របជូននិយោជិតខ្មែរ ។

៣- ការជំរុញលើកកំពស់ដល់និយោជិតខ្មែរ ដើម្បីអាចក្លាយទៅជាអ្នកមានឋានៈខ្ពស់ត្រូវធ្វើជាប្រចាំ ។

### មាត្រា ១៩.-

និយោជិតបរទេស ត្រូវបានអនុញ្ញាតអោយផ្ទេរទៅក្រៅប្រទេសនូវប្រាក់បៀវត្ស ដែលទទួលបាននៅក្នុងព្រះរាជាណាចក្រកម្ពុជា តាមរយៈប្រព័ន្ធធនាគារ ក្រោយពីបានបង់ពន្ធរួចហើយ ។

## ជំពូកទី ៨
## វិវាទ និង ការរំលាយ

មាត្រា ២០.-

វិវាទដែលទាក់ទងទៅនឹងកិច្ចការវិនិយោគនៅក្នុងព្រះរាជាណាចក្រកម្ពុជារបស់អ្នកវិនិ-យោគ ដែលពាក់ព័ន្ធទៅនឹងសិទ្ធិ និងភារកិច្ចដែលមានចែងក្នុងច្បាប់នេះអាច ៖

១- ដោះស្រាយដោយសម្រុះសម្រួលតាមរយៈការពិគ្រោះគ្នារវាងភាគីជំលោះទាំងម្ខាង ។

២- ក្នុងអំឡុងពេលពីរខែ បើវិវាទមិនបានដោះស្រាយតាមការសម្រុះសម្រួលគ្នាទេ វិវាទនេះអាច :

- លើកយកមកដាក់ជូនក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាផ្តល់យោបល់
- ដោះស្រាយតាមផ្លូវតុលាការនៃព្រះរាជាណាចក្រកម្ពុជា
- ឬដោះស្រាយតាមនីតិវិធីអន្តរជាតិណាមួយ តាមការព្រមព្រៀងនៃភាគី ។

មាត្រា ២១.-

ក្នុងករណីអ្នកវិនិយោគមានបំណងចង់បញ្ឈប់សកម្មភាពរបស់ខ្លួននៅក្នុងព្រះរាជាណាចក្រកម្ពុជា អ្នកវិនិយោគនោះ ត្រូវជូនពត៌មានទៅក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាតាមរយៈលិខិតអនុសិដ្ឋ ឬលិខិតប្រគល់ផ្ទាល់ដៃ ដោយមានបញ្ជាក់ថាបានទទួលត្រឹមត្រូវ ។ លិខិតខាងលើនេះ ត្រូវចុះហត្ថលេខាដោយអ្នកវិនិយោគឬអ្នកតំណាងពេញសិទ្ធិរបស់ក្រុមហ៊ុនហើយត្រូវបញ្ជាក់អំពីមូលហេតុនៃការបញ្ឈប់សកម្មភាពនោះផង ។

មាត្រា ២២.-

ក្នុងករណីដែលមានការសុំរំលាយក្រៅផ្លូវតុលាការ អ្នកវិនិយោគត្រូវផ្តល់ជូនក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា នូវលិខិតបញ្ជាក់ពីម្ចាស់បំណុល ពីអ្នកប្តឹងរបស់ខ្លួន និងពីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ថាបញ្ហាទាំងឡាយត្រូវបានដោះស្រាយចប់ជាស្ថាពរហើយ ទើបអ្នកវិនិយោគនោះអាចត្រូវបានអនុញ្ញាតអោយរំលាយក្រុមហ៊ុន ឬ សហគ្រាសរបស់ខ្លួនជាផ្លូវការបាន តាមបែបបទនៃច្បាប់ពាណិជ្ជកម្ម ។

មាត្រា ២៣.-

ក្នុងករណីដែលអ្នកវិនិយោគត្រូវបានអនុញ្ញាតអោយរំលាយក្រុមហ៊ុន ឬសហគ្រាសរបស់ខ្លួនជាផ្លូវការ ទោះតាមផ្លូវតុលាការក្តី ឬក្រៅផ្លូវតុលាការក្តី អ្នកវិនិយោគអាចផ្ទេរនូវទ្រព្យសម្បត្តិដែលសេសសល់ទៅក្រៅប្រទេស ឬមួយប្រើប្រាស់នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។ ចំពោះគ្រឿងម៉ាស៊ីន និង

សម្ភារៈបរិក្ខារដែលបានការអនុញ្ញាតអោយនាំចូលដោយរួចពន្ធហើយបានប្រើប្រាស់ក្នុងអំឡុងពេលតិចជាងប្រាំឆ្នាំ ( ៥ឆ្នាំ)អ្នកវិនិយោគត្រូវបង់ពន្ធតាមច្បាប់ជាធរមាន ។

## ជំពូកទី ៩

## អវសានបញ្ញត្តិ

មាត្រា ២៤._

ការវិនិយោគទាំងឡាយ ដែលបានទទួលការអនុញ្ញាត ក្រោមច្បាប់ស្តីពីការវិនិយោគនៅរដ្ឋកម្ពុជា និងអនុក្រិត្យស្តីពីការវិនិយោគរបស់បរទេសនៅរដ្ឋកម្ពុជា ត្រូវបានទទួលផលប្រយោជន៍ និងកាតព្វកិច្ចដូចមានចែងក្នុងច្បាប់នេះដែរ ប៉ុន្តែច្បាប់នេះពុំមានអានុភាពប្រតិសកម្មទេ ។

មាត្រា ២៥._

ក្នុងករណីដែលអ្នកវិនិយោគរំលោភ ឬមិនអនុវត្តតាមលក្ខខ័ណ្ឌទាំងឡាយដែលបានកំណត់ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាមានសិទ្ធិអំណាចដកហូតសិទ្ធិផ្សេងៗនិងផលប្រយោជន៍ទាំងអស់ ឬមួយផ្នែកដែលបានផ្តល់ជូនអ្នកវិនិយោគកន្លងមក ។

មាត្រា ២៦._

ច្បាប់នេះត្រូវប្រកាសជាការប្រញាប់ ។

ច្បាប់នេះត្រូវបានរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា
អនុម័តនៅថ្ងៃទី ០៤ ខែ សីហា ឆ្នាំ ១៩៩៤
នាសម័យប្រជុំវិសាមញ្ញនីតិកាលទី ១
ភ្នំពេញ.ថ្ងៃទី ០៤ ខែ សីហា ឆ្នាំ ១៩៩៤

**ប្រធានរដ្ឋសភាស្តីទី** ៦

លយ ស៊ីមឈាង